# អគ្គិសនីកម្ពុជា

## ELECTRICITE DU CAMBODGE

# របាយការណ៍ប្រចាំឆ្នាំ ២០១៣



# សេចក្តីថ្លែងការណ៍របស់ប្រធានក្រុមប្រឹក្សាភិបាល



តាងនាមឲ្យក្រុមប្រឹក្សាភិបាល ខ្ញុំសូមសំដែងនូវការកោតសរសើរយ៉ាងស្មោះចំពោះ អគ្គិសនីកម្ពុជា ដែលបានបញ្ចេញនូវរបាយការណ៍ប្រចាំឆ្នាំ ២០១៣ ។ យើងមានមោទនភាពចំពោះលទ្ធផល ដែលអគ្គិសនីកម្ពុជាសម្រេចបានអំឡុងឆ្នាំ ២០១៣ និងជឿជាក់យ៉ាងខ្លាំងថា អគ្គិសនីកម្ពុជានឹងឈានឆ្ពោះទៅកាន់ការសម្រេចបាននូវគោលដៅ និងចក្ខុវិស័យរបស់ខ្លួន ក្នុងគោលបំណង ដើម្បីឲ្យក្លាយជាក្រុមហ៊ុនឈានមុខគេលើវិស័យថាមពលនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយកសាងទំនាក់ទំនង និងសេវាកម្មល្អ ប្រកបដោយទំនុកចិត្ត ក្នុងការផ្គត់ផ្គង់អគ្គិសនីឲ្យបានគ្រប់គ្រាន់ និងតម្លៃសមរម្យជូនអតិថិជនរបស់ខ្លួន។

ក្នុងនាមជាប្រធានក្រុមប្រឹក្សាភិបាល ខ្ញុំមានសេចក្តីពេញចិត្តយ៉ាងខ្លាំង ចំពោះភាពជោគជ័យដ៏ធំធេងដែលនិយោជិត និយោជក របស់អគ្គិសនីកម្ពុជាសម្រេចបានក្នុងឆ្នាំកន្លងមក។ សមិទ្ធផលមានជាបន្តបន្ទាប់ប៉ុន្មានឆ្នាំកន្លងមកនេះ គឺជាសមិទ្ធផលដែលមិនធ្លាប់មានពីមុនមក។

ក្នុងឱកាសនេះ ខ្ញុំសូមសំដែងនូវអំណរគុណអស់ពីដួងចិត្តខ្ញុំផ្ទាល់ ចំពោះថ្នាក់ដឹកនាំ និងនិយោជិតអគ្គិសនីកម្ពុជាទាំងអស់ ដែលបានបំពេញការងារអស់ពីកម្លាំងកាយ និងកម្លាំងបញ្ញាស្មារតី ដែលធ្វើឲ្យសម្រេចបាននូវសមិទ្ធផលជាច្រើនកន្លងមក ដើម្បីឈានដល់ទិសដៅ និងចក្ខុវិស័យរបស់ខ្លួន។

**ប្រធានក្រុមប្រឹក្សាភិបាល**

**ទូន លាន**

# ពីប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា



ខ្ញុំមានមោទនភាព និងសូមបង្ហាញជូននូវរបាយការណ៍ប្រចាំឆ្នាំ២០១៣ ដែលអគ្គិសនីកម្ពុជាទទួលបាន ដោយផ្អែកលើចក្ខុវិស័យរបស់អគ្គិសនីកម្ពុជា គឺធ្វើយ៉ាងណាឲ្យក្លាយជាអង្គភាពអគ្គិសនីឈានមុខគេនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយត្រូវខិតខំយ៉ាងខ្លាំងក្នុងការបំពេញតម្រូវការប្រើប្រាស់ថាមពលអគ្គិសនី និងធ្វើឲ្យប្រសើរឡើងនូវគុណភាព និងប្រសិទ្ធភាពនៃការផ្គត់ផ្គង់ជូនអតិថិជន។

ក្នុងឆ្នាំ២០១៣ ការលក់ថាមពលអគ្គិសនីរបស់អគ្គិសនីកម្ពុជា បានកើនឡើងដល់ ៣.៤៨៣,៦៦ GWh ឬ ១២,៤៥% ច្រើនជាងឆ្នាំមុន ទន្ទឹមនឹងនោះ ការបាត់បង់លើប្រព័ន្ធទាំងមូល បានធ្លាក់ចុះមកនូវត្រឹម ៥,៦0%។ ចំណូលប្រចាំឆ្នាំមានការកើនឡើងដល់ ២.៦៧៤ ពាន់លានរៀល ឬ ១៧% ច្រើនជាងឆ្នាំមុន។ យើងមាននិយោជិតសរុបចំនួន ៣.២២៧ នាក់ សម្រាប់បម្រើសេវាកម្មជូនអតិថិជនចំនួន ៥០២.៨៥៩។

អំឡុងឆ្នាំ ២០១៣ រោងចក្រវារីអគ្គិសនីអាតៃ និងរោងចក្រអគ្គិសនីដើរដោយធ្យូងថ្ម ១០០ MW ត្រូវបានសាងសង់រួចជាស្ថាពរ និងដាក់ឲ្យដំណើរការ ដោយបានតភ្ជាប់ និងផ្គត់ផ្គង់ថាមពលទៅបណ្តាញជាតិតាមរយៈខ្សែបណ្តាញបញ្ជូនតង់ស្យុងខ្ពស់ ២៣០ kV កាត់តាមអនុស្ថានីយអូរសោម និងអនុស្ថានីយស្ទឹងហាវ មករាជធានីភ្នំពេញ។ វត្តមានរបស់រោងចក្រអគ្គិសនីទាំងពីរនេះ បានឆ្លើយតបទៅនឹងកង្វះថាមពលក្នុងឆ្នាំនេះ។

ខ្សែបញ្ជូនតង់ស្យុងខ្ពស់ ២៣០ kV ពីខេត្តកំពត ទៅខេត្តព្រះសីហនុ ស្ថិតក្រោមប្រាក់កម្ចីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) មានប្រវែង ៨៨ km និងខ្សែបញ្ជូនតង់ស្យុងខ្ពស់ ២៣០ kV មួយខ្សែទៀតពីភ្នំពេញ ទៅខេត្តកំពង់ចាម ដែលមានប្រវែង ១១០ km ត្រូវបានដាក់ឲ្យដំណើរការ។ គម្រោងទាំងនេះ បានធ្វើឲ្យបណ្តាញជាតិគ្របដណ្តប់លើខេត្តចំនួន ២ បន្ថែមទៀតរួមមានខេត្តព្រះសីហនុ និងខេត្តកំពង់ចាម។

ដោយអនុលោមតាមយុទ្ធសាស្រ្ត និងមានការគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជា (មូលនិធិរបស់រាជរដ្ឋាភិបាល) លើវិស័យអគ្គិសនីភាវូបនីយកម្មជនបទ អគ្គិសនីកម្ពុជា បានទាក់ទាញនូវប្រាក់ជំនួយឥតសំណង និងប្រាក់កម្ចីផ្សេងៗ ដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍រួមមានៈ មូលនិធិអាល្លឺម៉ង់ (KfW) ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) អូស្ស្រអេត (Aus-Aid) និងធនាគារចិនអ៊ិចស៊ីម (China Exim Bank) បានដំណើរការនូវគម្រោងពង្រីកបណ្តាញសម្រាប់អគ្គិសនីភាវូបនីយកម្មជនបទនៅតំបន់ជាច្រើន នៃព្រះរាជាណាចក្រកម្ពុជា ដែលក្នុងនោះខេត្តចំនួន ១៥ កំពុងស្ថិតក្រោមការសិក្សាជាមួយបណ្តាញប្រវែងសរុបជាង ៦.000 km ។

ជាពិសេសគម្រោងអគ្គិសនីភាវូបនីយកម្មជនបទ ដែលស្ថិតក្រោមប្រាក់កម្ចីរបស់ធនាគារចិនអ៊ិចស៊ីម (China Exim Bank) កំពុងដំណើរការសាងសង់ប្រព័ន្ធចែកចាយតង់ស្យុងមធ្យម និងបំពាក់ត្រង់ស្វូម៉ាទ័រ ហើយរំពឹងថានឹងសាងសង់រួចរាល់ជាស្ថាពរក្នុងឆ្នាំ ២០១៤ ដែលគ្របដណ្តប់ខេត្តចំនួន ០៤ ដូចជា ខេត្តកំពង់ចាម ខេត្តព្រៃវែង ខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ ដែលមានប្រវែងសរុប ២.000 km ។ បន្ថែមពីនេះ គម្រោងអគ្គិសនីភាវូបនីយកម្មជនបទ ស្ថិតក្រោមគម្រោងមូលនិធិអាល្លឺម៉ង់ (KfW) និងមូលនិធិរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលគ្របដណ្តប់ខេត្តចំនួន ៩ ដូចជា ខេត្តតាកែវ ខេត្តកំពត ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ក្រុងប៉ៃលិន ខេត្តឧត្តរមានជ័យ ខេត្តព្រះវិហារ និងខេត្តស្វាយរៀង ដែលមានប្រវែងសរុបប្រមាណ ៩.៥00 km បានចាប់ផ្តើមសាងសង់ ហើយរំពឹងថារួចរាល់ជាស្ថាពរនៅឆ្នាំ ២០១៩។

លើសពីនេះទៅទៀត បណ្តាអ្នកកាន់អាជ្ញាប័ណ្ណ (សេវាករ) បម្រើសេវាចែកចាយអគ្គិសនីចំនួន ១២៣ បានចុះកិច្ចព្រមព្រៀងលក់-ទិញថាមពលអគ្គិសនីជាមួយអគ្គិសនីកម្ពុជា ដោយភ្ជាប់ជាមួយបណ្តាញរបស់

អគ្គិសនីកម្ពុជា ដើម្បីផ្គត់ផ្គង់អគ្គិសនីនៅក្នុងតំបន់អាជ្ញាប័ណ្ណរបស់ខ្លួន ដោយបានបញ្ឈប់ឲ្យដំណើរការនូវម៉ាស៊ីនភ្លើងតូចៗ របស់ខ្លួន ដែលជាប្រភពប្រើប្រាស់ប្រេងមានតម្លៃខ្ពស់។

នៅក្នុងឆ្នាំនេះដែរ អគ្គិសនីកម្ពុជាបានផ្តល់ជំនួយឥតសំណងចំនួន ៤ លានដុល្លារអាមេរិក ទៅកាន់នាយកដ្ឋានមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ ដើម្បីបន្តការជំរុញ និងអភិវឌ្ឍន៍វិស័យអគ្គិសនីភាវូបនីយកម្មជនបទទូទាំងប្រទេស តាមរយៈគោលនយោបាយឧបត្ថម្ភធនរបស់អគ្គិសនីកម្ពុជា។

លទ្ធផលនៃកិច្ចខំប្រឹងប្រែងខាងលើ បានផ្តល់នូវប្រយោជន៍ដោយផ្ទាល់ និងដោយប្រយោលជាច្រើនជូនដល់ប្រជាជនរាប់សែនគ្រួសារ រួមទាំងការទាក់ទាញការវិនិយោគនៅទូទាំងប្រទេស ដែលប្រការទាំងនេះបានឆ្លុះបញ្ចាំងឲ្យឃើញពីភាពរឹងមាំ និងការរីកចម្រើនឥតឈប់ឈរ ក្នុងការរួមចំណែកអភិវឌ្ឍន៍ប្រទេសកម្ពុជា ដើម្បីស្ថាបនាបាននូវគ្រឹះដ៏រឹងមាំ សម្រាប់កិច្ចអភិវឌ្ឍន៍ឲ្យមាននិរន្តភាពសេដ្ឋកិច្ច និងសង្គមជាតិ។

ឆ្លៀតក្នុងឱកាសនេះ យើងខ្ញុំសូមធ្វើការកត់សម្គាល់ពីការចូលរួមចំណែក និងការប្តេជ្ញាចិត្តដ៏មុះមុតរបស់និយោជិតយើងទាំងអស់គ្នា ដែលបានដើរតួនាទីដ៏សំខាន់ និងមិនអាចខ្វះបានក្នុងការសម្រេចបានជោគជ័យជូនអង្គភាពនេះ។ យើងខ្ញុំសូមសម្តែងនូវកតញ្ញូដ៏ជ្រាលជ្រៅ ចំពោះការណែនាំដ៏មានសារៈសំខាន់ប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលសម្តេចតែងផ្តល់ការគាំទ្រជាគន្លឹះៗ នៅគ្រប់របត់សំខាន់ៗ ទាំងអស់។

យើងខ្ញុំសូមសម្តែងនូវការដឹងគុណ ចំពោះក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានបន្តចង្អុលបង្ហាញទិសដៅ និងគាំទ្រយ៉ាងខ្លាំងក្លា ។ យើងខ្ញុំសូមសំដែងនូវសេចក្តីសោមនស្សរីករាយ ជាពិសេសជូនដល់អាជ្ញាធរអគ្គិសនីកម្ពុជា សម្រាប់ការចូលរួមចំណែក និងការគាំទ្រចំពោះសមាជិកក្រុមប្រឹក្សាភិបាលអគ្គិសនីកម្ពុជា សម្រាប់ការណែនាំកន្លងមក ។ យើងខ្ញុំសូមវាយតម្លៃយ៉ាងខ្ពស់ផងដែរ ចំពោះការគាំទ្រពីសំណាក់អតិថិជនគ្រប់ប្រភេទរបស់អគ្គិសនីកម្ពុជា ជាងនេះទៅទៀត យើងខ្ញុំសូមសម្តែងនូវការកោតសរសើរ ចំពោះដៃគូអភិវឌ្ឍន៍នានា និងដៃគូអ្នកផលិតថាមពលឯករាជ្យទាំងអស់ក្នុងការជួយជ្រោមជ្រែង និងសហការគ្នាយ៉ាងជិតស្និទ្ធជាបន្តបន្ទាប់ ។

ដោយទទួលបានសមិទ្ធផល និងការលើកទឹកចិត្តទាំងនេះ យើងខ្ញុំបានត្រៀមខ្លួន ដើម្បីដឹកនាំអគ្គិសនីកម្ពុជា និងវិស័យថាមពល ឲ្យមានការអភិវឌ្ឍន៍ឈានដល់កម្រិតអតិបរមា ។ យើងខ្ញុំមានសង្ឃឹមដ៏មុតមាំថា នាថ្ងៃអនាគត វិស័យថាមពល នឹងមានសន្ទុះដ៏ប្រសើរបំផុត។

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**
**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**

**កែវ រតនៈ**

## ចក្ខុវិស័យ

ចក្ខុវិស័យរបស់អគ្គិសនីកម្ពុជា គឺធ្វើយ៉ាងណាឲ្យក្លាយជាអង្គភាពអគ្គិសនី ឈានមុខគេនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយត្រូវខិតខំយ៉ាងខ្លាំង ក្នុងការបំពេញតម្រូវការប្រើប្រាស់ថាមពលអគ្គិសនី និងធ្វើឲ្យប្រសើរឡើងនូវគុណភាព និងប្រសិទ្ធភាពនៃការផ្គត់ផ្គង់ថាមពលអគ្គិសនីជូនអតិថិជន។

## ទស្សនវិស័យ

ផ្តល់ការផ្គត់ផ្គង់អគ្គិសនីឲ្យបានគ្រប់គ្រាន់ ប្រកបដោយ ស្ថេរភាព គុណភាព ប្រសិទ្ធភាព ជូនអតិថិជននៅក្នុងតំបន់ដែលមានអាជ្ញាប័ណ្ណរបស់ខ្លួន ដោយតម្លៃប្រកួតប្រជែង។ បង្កើនប្រតិបត្តិការអាជីវកម្មឲ្យបានប្រសើរបំផុត និងប្រកបដោយប្រសិទ្ធភាព និងឧត្តមភាព និងចូលរួមអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលដើម្បីកាត់បន្ថយភាពក្រីក្រ ការពារបរិស្ថាន និងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម។

## តួនាទី និងការទទួលខុសត្រូវ

អគ្គិសនីកម្ពុជាមានសិទ្ធិ និងការទទួលខុសត្រូវចំពោះការផលិត បញ្ជូន និងចែកចាយ ថាមពលអគ្គិសនីទូទាំងព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមតាមកាតព្វកិច្ចនៃការធ្វើពាណិជ្ជកម្មរបស់ខ្លួនដែលមានចែងនៅក្នុងច្បាប់លក្ខន្តិកៈ អាជ្ញាប័ណ្ណ និងបទបញ្ញត្តិដទៃទៀតរបស់រាជរដ្ឋាភិបាលកម្ពុជា។

អគ្គិសនីកម្ពុជា ប្រតិបត្តិជាសហគ្រាសពាណិជ្ជកម្មមួយ មានឯករាជ្យភាព ក្នុងការរៀបចំអាជីវកម្មរបស់ខ្លួនលើការផលិត បញ្ជូន និងចែកចាយថាមពលអគ្គិសនី និងបង្កើតទុនវិនិយោគ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារ និងមានការទទួលខុសត្រូវលើចំណូល ចំណាយ។

អគ្គិសនីកម្ពុជា ត្រូវអនុវត្តន៍តាមល័ក្ខខ័ណ្ឌរបស់អាជ្ញាប័ណ្ណ ចេញដោយអាជ្ញាធរអគ្គិសនីកម្ពុជា ដើម្បីផ្តល់សេវាកម្មអគ្គិសនី។ អគ្គិសនីកម្ពុជា ត្រូវអនុវត្តន៍ នឹងធ្វើឲ្យសម្រេចនូវផែនការអាជីវកម្មរបស់ខ្លួន ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាលអគ្គិសនីកម្ពុជា និងអនុលោមតាមគោលនយោបាយថាមពលអគ្គិសនីជាតិ និងផែនការអភិវឌ្ឍន៍ជាតិ ។

អគ្គិសនីកម្ពុជា ត្រូវកំណត់សកម្មភាពអាជីវកម្ម ដែលមានចែងនៅក្នុងលក្ខន្តិកៈ និងអាជ្ញាប័ណ្ណដែលបានអនុម័តដោយអាជ្ញាធរអគ្គិសនីកម្ពុជា។

អគ្គិសនីកម្ពុជា ត្រូវបានអនុញ្ញាតលើការទទួលខុសត្រូវចំពោះ ៖

១ ការផលិត ការបញ្ជូន និងការបែងចែកថាមពលអគ្គិសនី ក្នុងគោលបំណង ដើម្បីឆ្លើយតបតាមតម្រូវការថាមពលរបស់អ្នកជាវគ្រប់ប្រភេទ។

២ ការនាំចូល និងនាំចេញ ថាមពលអគ្គិសនី ជាមួយប្រទេសជិតខាង ។

៣ ការសាងសង់ និងដាក់ឲ្យដំណើរការបណ្តាញជាតិបញ្ជូនអគ្គិសនី ដើម្បីធានានូវការផ្គត់ផ្គង់អគ្គិសនីឲ្យបានគ្រប់គ្រាន់ និងមានគុណភាព។

៤ ការសាងសង់ និងដាក់ឲ្យដំណើរការបណ្តាញបញ្ជូនរង ក្នុងគោលបំណង ចែកចាយអគ្គិសនី និងផ្គត់ផ្គង់ដល់តំបន់គ្រប់គ្រងដោយអគ្គិសនីកម្ពុជា និងតំបន់ដទៃទៀត។

៥ ការលក់ថាមពលអគ្គិសនី និងការបម្រើសេវាកម្មដែលពាក់ព័ន្ធ ។

៦ ការទិញថាមពល ការបញ្ជូនថាមពល និងការទិញ-លក់ថាមពល រវាងអគ្គិសនីកម្ពុជា និងដៃគូអ្នកផលិតថាមពលឯករាជ្យផ្សេងៗទៀត។

អគ្គិសនីកម្ពុជា បានប្រភពទុនមកពី ៖

១ ការផ្តល់ជំនួយពីរាជរដ្ឋាភិបាលកម្ពុជា ។

២ អចលនទ្រព្យនិងដីធ្លីទាំងឡាយ ដែលត្រូវបានផ្ទេរជូនអគ្គិសនីកម្ពុជា ដោយរាជរដ្ឋាភិបាល ដូចមាននៅក្នុងមាត្រាទី៧ នៃអនុក្រឹត្យ លេខ ២៣។

៣ ប្រាក់ចំណូល ដោយយោងតាមគោលការណ៍គណនេយ្យរបស់អគ្គិសនីកម្ពុជា ។

៤ ការផ្តល់ហិរញ្ញប្បទានឥតសំណង និងហិរញ្ញប្បទានឥណទានផ្សេងៗ ដែលអគ្គិសនីកម្ពុជាបានទទួលដោយមានការអនុម័តពីរាជរដ្ឋាភិបាល ។

៥ ការផ្តល់ឥណទានដល់អគ្គិសនីកម្ពុជាពីប្រភពហិរញ្ញវត្ថុផ្សេងៗ ដែលត្រូវអនុម័តដោយរាជរដ្ឋាភិបាល ។

## ការវិវត្តន៍របស់អគ្គិសនីកម្ពុជា

ការប្រើប្រាស់អគ្គិសនី មាននវត្តមាននៅប្រទេសកម្ពុជា ក្នុងឆ្នាំ១៩០៦ ។ មុនខែ តុលា ឆ្នាំ ១៩៥៨ ថាមពលអគ្គិសនី និងការប្រើប្រាស់សម្រាប់បំភ្លឺផ្សេងៗ នៅប្រទេសកម្ពុជា ត្រូវបានផ្គត់ផ្គង់ដោយក្រុមហ៊ុនឯកជនចំនួន ០៣ ៖

- ក្រុមហ៊ុនទឹក និងអគ្គិសនី ហៅកាត់ថា CEE

- សហព័ន្ធអគ្គិសនីឥណ្ឌូចិន ហៅកាត់ថា UNEDI

- ក្រុមហ៊ុនអគ្គិសនីបារាំង-ខ្មែរ ហៅកាត់ថា CFKE

ក្រុមហ៊ុនទឹក និងអគ្គិសនី (CEE) បានបម្រើសេវាអគ្គិសនីយ៉ាងធំនៅតំបន់ទីក្រុងភ្នំពេញ។ សហព័ន្ធអគ្គិសនីឥណ្ឌូចិន (UNEDI) ទទួលខុសត្រូវគ្រប់បណ្តាខេត្តផ្សេងៗទាំងអស់ លើកលែងតែខេត្តបាត់ដំបងដែលត្រូវបានផ្គត់ផ្គង់អគ្គិសនីដោយ ក្រុមហ៊ុនអគ្គិសនីបារាំង-ខ្មែរ (CFKE)។

យោងតាមក្រិតលេខ: ៦៦៥-NS ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៥៨ ក្រុមហ៊ុនចំនួនពីរគឺ ក្រុមហ៊ុនទឹក និងអគ្គិសនី (CEE) និងសហព័ន្ធអគ្គិសនីឥណ្ឌូចិន (UNEDI) បានដាក់បញ្ចូលគ្នា ដោយដាក់ឈ្មោះថា **អគ្គិសនីកម្ពុជា** ។

អំឡុងឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៩ វិស័យថាមពលអគ្គិសនីនៅក្នុងប្រទេសបានឆ្លងកាត់ព្រឹត្តិការណ៍ចំនួនពីរដែលទទួលរងគ្រោះថ្នាក់ដោយសារ ៖សង្គ្រាមស៊ីវិល (ពីឆ្នាំ១៩៧០ - ១៩៧៥) និងមានភាពចលាចលជាប្រវត្តិសាស្ត្រ អំឡុងរបបខ្មែរក្រហម (ពីឆ្នាំ១៩៧៥ - ១៩៧៩)។ អំឡុងពេលនោះ មធ្យោបាយនៃការផលិត ការបញ្ជូន និងការចែកចាយ គ្រប់ប្រភេទទាំងអស់ត្រូវបានបំផ្លាញ មិនត្រឹមតែនៅរាជធានីភ្នំពេញទេ ប៉ុន្តែថែមទាំងនៅតំបន់ដទៃៗទៀតផងដែរ។

នៅឆ្នាំ១៩៧៩ អគ្គិសនីកម្ពុជា ត្រូវបានបង្កើតឡើងវិញ ដោយរចនាសម្ព័ន្ធរដ្ឋបាល ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងឧស្សាហកម្ម។ នៅឆ្នាំ ១៩៩១ អគ្គិសនីកម្ពុជា ត្រូវបានផ្ទេរឲ្យស្ថិតក្រោមការគ្រប់គ្រងរបស់សាលារាជធានីភ្នំពេញ ដោយដាក់ឈ្មោះថា អគ្គិសនីភ្នំពេញ ហើយមានភារកិច្ចក្នុងការផ្គត់ផ្គង់អគ្គិសនីនៅរាជធានីភ្នំពេញ ទន្ទឹមនឹងនោះ ការផ្គត់ផ្គង់អគ្គិសនីនៅតាមបណ្តាខេត្តទាំងអស់ ត្រូវបានគ្រប់គ្រងដោយមន្ទីរឧស្សាហកម្មខេត្ត។

នៅឆ្នាំ ១៩៩២ អគ្គិសនីភ្នំពេញ ត្រូវបានផ្ទេរឲ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងឧស្សាហកម្ម ដោយប្តូរឈ្មោះជាថ្មីទៅជាអគ្គិសនីកម្ពុជាវិញ ។ ក្រោយពីការបោះឆ្នោតជាសកលនៅឆ្នាំ១៩៩៣ អគ្គិសនីកម្ពុជា ត្រូវបានធ្វើកំណែទម្រង់ ឲ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ហើយទទួលខុសត្រូវសម្រាប់ការផ្គត់ផ្គង់ថាមពលអគ្គិសនីនៅរាជធានីភ្នំពេញ។ ចំណែកឯ អង្គភាពបម្រើសេវាកម្មថាមពលអគ្គិសនីនៅតាមបណ្តាខេត្តមួយចំនួន នៅតែស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរខេត្តប៉ុន្តែទទួលការឧបត្ថម្ភថវិកាតាមរយ:ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។

នៅខែមីនា ឆ្នាំ១៩៩៦ តាមព្រះរាជក្រឹត្យលេខ ០៣៩៦/១០ អគ្គិសនីកម្ពុជា បានក្លាយជាក្រុមហ៊ុនស្វយ័ត ទទួលខុសត្រូវមានកំណត់មួយ ជាកម្មសិទ្ធិរបស់រដ្ឋទាំងមូល ដែលមានកាតព្វកិច្ចក្នុងការផលិតបញ្ជូន និងចែកចាយថាមពលអគ្គិសនីទូទាំងព្រះរាជាណាចក្រកម្ពុជា ។ អគ្គិសនីកម្ពុជា ជាស្ថាប័នមួយស្របច្បាប់ ដោយមានស្វ័យភាពនៃការគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុ ។ អគ្គិសនីកម្ពុជា ទទួលខុសត្រូវចំពោះប្រាក់ចំណេញ ប្រាក់ខាតបង់ និងទទួលសងបំណុលទៅតាមទំហំនៃតម្លៃទ្រព្យសម្បត្តិរបស់ខ្លួន។

## រចនាសម្ព័ន្ធគ្រប់គ្រង

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺជាម្ចាស់សហកម្មសិទ្ធិលើក្រុមហ៊ុនអគ្គិសនីកម្ពុជា។

## ក្រុមប្រឹក្សាភិបាល

ឆ្នាំ ២០១៣ ក្រុមប្រឹក្សានៃអគ្គិសនីកម្ពុជា មានសមាជិកចំនួន ០៧ រូប



**ឯកឧត្តម ទុន លាន**

ប្រធាន

តំណាង ក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល



**ឯកឧត្តម កែវ រតនៈ**

សមាជិក

ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា (ទីប្រឹក្សាផ្ទាល់របស់ សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា)



**ឯកឧត្តម ចាន់ សុធី**

សមាជិក

តំណាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



**ឯកឧត្តម ហែម ក្រាញ តូនី**

សមាជិក

តំណាង ទីស្តីការគណៈរដ្ឋមន្ត្រី



**លោក ហង់ ទូច**

សមាជិក

តំណាង និយោជិតកម្មករ អគ្គិសនីកម្ពុជា



**លោក គួ ខែមលីន**
សមាជិក
តំណាង ក្រសួងយុត្តិធម៌



**លោកស្រី សុខ សុធាវី**
សមាជិក
តំណាង សមាពាណិជ្ជកម្មកម្ពុជា

## ការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជា

អគ្គិសនីកម្ពុជា ត្រូវបានដឹកនាំដោយប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា ដោយមានឋានៈស្មើនឹងរដ្ឋលេខាធិការក្នុងជួររាជរដ្ឋាភិបាល ដែលជាអ្នករាយការណ៍ជូនក្រុមប្រឹក្សាភិបាល និងទទួលរបាយការណ៍ត្រឡប់មកវិញ ដើម្បីរាយការណ៍ជូនទៅ រដ្ឋមន្ត្រីក្រសួងអាណាព្យាបាលទាំងពីរ។ ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា ត្រូវបានជួយការងារ ដោយអគ្គនាយករង ចំនួន ០៤ រូប និងនាយក ចំនួន ០៩ រូប ។ ឆ្នាំ ២០១៣ ថ្នាក់គ្រប់គ្រងរបស់អគ្គិសនីកម្ពុជា រួមមាន៖



**ឯកឧត្តម កែវ រតនៈ**
ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា
ទីប្រឹក្សាផ្ទាល់របស់ សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា



**ឯកឧត្តម ចាន់ សុជាវ៉ាត**
អគ្គនាយករង
ផែនការ និងបច្ចេកទេស



**លោក ឆឹង អ៊ីង**
អគ្គនាយករង
ហិរញ្ញកិច្ច-អាជីវកម្ម



**ឯកឧត្តម អេង គន្ធា**
អគ្គនាយករង
រដ្ឋបាល



**លោក កែវ វីរៈ**
អគ្គនាយករង
មូលនិធិអគ្គិសនីតាវូបនីយកម្មជនបទ



**បណ្ឌិត ប្រាំង ជលសា**

នាយក ផែនការយុទ្ធសាស្ត្រ និងគម្រោងការ



**កញ្ញា ស៊ិន សុវណ្ណនី**

នាយិកា ហិរញ្ញកិច្ច-គណនេយ្យ



**លោក លី ទីឃា**

នាយក រដ្ឋបាល



**លោក នូ សុខុន**

នាយក បញ្ជូនអគ្គិសនី



**លោក អូន ហេមរិទ្ធ**

នាយក ផលិតកម្ម



**លោក ជា ស៊ីនហ៊ើល**

នាយក អាជីវកម្ម-ចែកចាយ



**លោក ង៉ែត សុខន**

នាយក លទ្ធកម្ម



**លោក អ៊ុំ ពិសិដ្ឋ**

នាយក វិទ្យាស្ថានវិទ្យាសាស្ត្រអគ្គិសនី



**លោក លឿង កែវសិលា**

នាយក មូលនិធិអគ្គិសនីតាវ៉ូបនីយកម្មជនបទ

# អង្គការលេខ និងរចនាសម្ព័ន្ធគ្រប់គ្រង អគ្គិសនីកម្ពុជា



## ការអភិវឌ្ឍន៍ធនធានមនុស្ស

នៅឆ្នាំ២០១៣ វិទ្យាស្ថានវិទ្យាសាស្ត្រអគ្គិសនី បានបណ្តុះបណ្តាលដល់សិក្ខាកាមជានិយោជិតមកពីនាយកដ្ឋាន និងអង្គភាពអគ្គិសនីខេត្ត-ក្រុងចំនួន ១.០០១ នាក់ លើវគ្គជំនាញចំនួន ១៥៤ វគ្គ និង ៨៣ មុខវិជ្ជា។ សិក្ខាកាមទាំងនោះ ត្រូវបានបណ្តុះបណ្តាលលើជំនាញផ្សេងៗគ្នា ក្នុងនោះរួមមាន៖ សិក្ខាកាម ៣៨៣ នាក់ ខាងផ្នែកបណ្តាញចែកចាយ សិក្ខាកាម ៨៤នាក់ ខាងផ្នែកប្រព័ន្ធការពាររោងចក្រផលិតអគ្គិសនី សិក្ខាកាម ១៦១ នាក់ ខាងផ្នែកនាឡិកាស្ទង់ សិក្ខាកាម ១២៤ នាក់ ខាងផ្នែកសុវត្ថិភាពពលកម្ម សិក្ខាកាម ១០២ នាក់ ខាងផ្នែកផលិតថាមពល សិក្ខាកាម ៤៧ នាក់ ខាងផ្នែកបណ្តាញបញ្ជូនតង់ស្យុងខ្ពស់ សិក្ខាកាម ៩៥ នាក់ ខាងផ្នែកកម្មវិធីកុំព្យូទ័រ និងសិក្ខាកាម ៤៥ នាក់ ខាងផ្នែកភាសាអង់គ្លេសបច្ចេកទេស ។

អគ្គិសនីកម្ពុជា ក៏បានសហការជាមួយស្ថាប័នជាតិ និងអន្តរជាតិដទៃទៀត ក្នុងការផ្តល់នូវវគ្គបណ្តុះបណ្តាលវិស័យថាមពលអគ្គិសនី ដើម្បីបង្កើនចំណេះដឹង និងបច្ចេកវិទ្យាថ្មីៗ ដល់និយោជិតរបស់ខ្លួន។

### តារាងទី ១ : និយោជិត-កម្មករ អគ្គិសនីកម្ពុជាពីឆ្នាំ ២០០៨ - ២០១៣

| ប្រភេទ | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|---|
| បណ្ឌិត | ១ | ១ | ១ | ២ | ៣ | ៤ |
| អនុបណ្ឌិត | ៨៥ | ៩១ | ១០៤ | ១១៩ | ១៤២ | ១៩១ |
| វិស្វករ និងបរិញ្ញាប័ត្រផ្សេងៗ | ៣៩០ | ៤៤៦ | ៥៥១ | ៦៧២ | ៨២២ | ៩៣៤ |
| បច្ចេកទេសជំនាញ | ៣៥១ | ៣៥៨ | ៣៩០ | ៤២៩ | ៤៩៣ | ៥៧០ |
| កម្មករជំនាញ | ២៤៧ | ២៤៥ | ២៤៦ | ២០៧ | ១៩៨ | ១៩០ |
| ទុតិយភូមិ និង គ្មានជំនាញ | ១.១៦៧ | ១.២១៩ | ១.២៧៨ | ១.៣៣១ | ១.២៨៧ | ១.៣៩៨ |
| សរុប | ២.២៤១ | ២.៣៦០ | ២.៥៧០ | ២.៧៦០ | ២.៩៣៥ | ៣.២២៧ |

ចក្ខុវិស័យរបស់អគ្គិសនីកម្ពុជា សម្រាប់និយោជិតរបស់ខ្លួន គឺមានដូចខាងក្រោម ៖

- ផ្តល់ឲ្យនិយោជិតរបស់ខ្លួន មានឱកាស ដើម្បីពង្រឹងសមត្ថភាពវិជ្ជាជីវៈ ដោយផ្តោតលើសមត្ថភាពការងារ ភាពសុចរិត និងភាពស្មោះត្រង់ចំពោះអគ្គិសនីកម្ពុជា។
- ផ្តល់ឲ្យនិយោជិតរបស់ខ្លួន នូវស្ថានភាពជីវភាពរស់នៅបានល្អ និងសមរម្យ
- ធានានូវភាពត្រឹមត្រូវ ស្មើភាព និងផ្តល់ឱកាសដល់និយោជិតទាំងឡាយ ដើម្បីទទួលបាននូវការចូលរួមចំណែកក្នុងការអភិវឌ្ឍន៍អគ្គិសនីកម្ពុជា។
- ផ្តល់ជូននូវល័ក្ខខ័ណ្ឌការងារល្អសមរម្យ ដោយបើកទូលាយក្នុងការប្រាស្រ័យទាក់ទងព័ត៌មាន ប្រកបដោយភាពស្មោះត្រង់ ក្នុងចំណោមនិយោជិតទាំងអស់ និងជួយជំរុញលើការចូលរួមធ្វើការជាក្រុមក្នុងគោលបំណងបង្កើនប្រសិទ្ធភាពការងារ ដោយផ្តោតលើទិសដៅស្ថាបនាក្រុមហ៊ុនឲ្យមានការរីកចម្រើន។

## ការនាំចូលអគ្គិសនីតង់ស្យុងខ្ពស់ពីប្រទេសថៃឡង់ដ៍ និងវៀតណាម

អគ្គិសនីកម្ពុជា បាននាំថាមពលអគ្គិសនីពីប្រទេសថៃឡង់ដ៍ តាមរយៈខ្សែបណ្តាញតង់ស្យុង ១១៥ kV តាមច្រកអារញ្ញប្រាថេតប្រទេសថៃឡង់ដ៍ មកខេត្តបន្ទាយមានជ័យនៃប្រទេសកម្ពុជា ដើម្បីផ្គត់ផ្គង់ដល់ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង និងខេត្តសៀមរាប ចាប់ពីខែវិច្ឆិកា ឆ្នាំ ២០០៧ ។ អំឡុងឆ្នាំ ២០១៣ តាមខ្សែបណ្តាញខាងលើ អគ្គិសនីកម្ពុជា បាននាំថាមពលអគ្គិសនីបរិមាណ ៩១៦.៩៧៤.៥០០ kWh ពីប្រទេសថៃឡង់ដ៍។

ពីប្រទេសវៀតណាម តាមរយៈបណ្ដាញខ្សែបញ្ជូនតង់ស្យុង ២៣០ kV ចំនួន ០២ សៀគ្វី អគ្គិសនីកម្ពុជា បាននាំថាមពលមកផ្គត់ផ្គង់នៅខេត្តតាកែវ នៅថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៩ និងរាជធានីភ្នំពេញ នៅថ្ងៃទី ០៨ ខែឧសភា ឆ្នាំ២០០៩ ។ តាមរយៈខ្សែបញ្ជូននេះ នៅឆ្នាំ២០១៣ អគ្គិសនីកម្ពុជា បាននាំថាមពលអគ្គិសនីមានបរិមាណ ១.៣២៩.១១៦.៧៥៧ kWh។ បណ្ដាញខ្សែបញ្ជូននេះ បានភ្ជាប់ទៅខ្សែបណ្ដាញបញ្ជូន និងអនុស្ថានីយមួយចំនួនទៀត ដែលបានសាងសង់រួចពីខេត្តបាត់ដំបងមក ខេត្តពោធិ៍សាត់ ខេត្តកំពង់ឆ្នាំង និងរាជធានីភ្នំពេញ ។ បណ្ដាញនេះ នឹងត្រូវភ្ជាប់ជាមួយបណ្ដាញបញ្ជូនមួយចំនួនទៀត ដែលកំពុងស្ថិតក្នុងការសាងសង់ ដូចជា បណ្ដាញ ២៣០ kV ពីខេត្តតាកែវ ទៅខេត្តកំពត, បណ្ដាញពីខេត្តកំពត ទៅខេត្តព្រះសីហនុ និងបណ្ដាញពីរាជធានីភ្នំពេញ ទៅខេត្តកំពង់ចាមជាដើម ហើយបណ្ដាញខ្សែបញ្ជូនទាំងមូលនេះនឹងក្លាយទៅជាបណ្ដាញជាតិបញ្ជូន ។

## តម្រូវការថាមពល និងការផ្គត់ផ្គង់អគ្គិសនី នៅក្នុងតំបន់គ្រប់គ្រងដោយអគ្គិសនីកម្ពុជា

តំបន់ដែលគ្រប់គ្រងដោយអគ្គិសនីកម្ពុជា នៅឆ្នាំ២០១៣ មានចំនួន ១៥ តំបន់ ដែលស្ថិតនៅក្នុងខេត្ត-ក្រុងផ្សេងៗ ដូចមានខាងក្រោម៖

**អគ្គិសនីភ្នំពេញ (ប្រព័ន្ធភ្នំពេញ)** ភ្នំពេញ គឺជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងរបាយការណ៍នេះ ប្រព័ន្ធអគ្គិសនីភ្នំពេញ ផ្គត់ផ្គង់ពីអនុស្ថានីយទី១, អនុស្ថានីយទី២, អនុស្ថានីយទី៣, អនុស្ថានីយទី៤, អនុស្ថានីយទី៥, អនុស្ថានីយទី៦ ដែលស្ថិតក្នុងការគ្រប់គ្រងរបស់អគ្គិសនីភ្នំពេញ រួមមាន រាជធានីភ្នំពេញ តំបន់ជាយក្រុង ជុំវិញក្រុងភ្នំពេញ និងមានក្នុងទីប្រជុំជនខេត្តកណ្ដាល។

ប្រព័ន្ធអគ្គិសនីភ្នំពេញ ត្រូវបានផ្គត់ផ្គង់ពីបណ្ដាញជាតិបញ្ជូន រោងចក្រផលិតថាមពលឯករាជ្យ (IPPs) និងរោងចក្រអគ្គិសនីរបស់អគ្គិសនីកម្ពុជា ។ អានុភាពតម្លើងរបស់រោងចក្រផលិតថាមពលឯករាជ្យ (IPPs) គឺ ៩៧៥,៥៨ MW អានុភាពនាំចូលពីប្រទេសវៀតណាម ប្រមាណ ១៧០ MW និងអានុភាពតម្លើងរបស់អគ្គិសនីកម្ពុជា (EDC) គឺមាន ៥៤ MW ដែលភាគច្រើនប្រើសម្រាប់បម្រុងទុក។

នៅឆ្នាំ២០១៣ តម្រូវការអានុភាពអតិបរមារបស់ប្រព័ន្ធភ្នំពេញគឺ ៥៩៤,៧០ MW ។ ការផ្គត់ផ្គង់ថាមពលពីការផលិតដោយរោងចក្រអគ្គិសនី និងការនាំចូលមកប្រព័ន្ធអគ្គិសនីភ្នំពេញ បានកើនឡើងពី ២.៤៧៩,៧៣ GWh ក្នុងឆ្នាំ ២០១២ ទៅ ២.៧៥៧,៤២ GWh ក្នុងឆ្នាំ២០១៣ ហើយការបាត់បង់ថាមពលនៅលើប្រព័ន្ធបានថយចុះពី ៨,៦៣ % ក្នុងឆ្នាំ២០១២ ទៅ ៨,២៣% ក្នុងឆ្នាំ ២០១៣។

**អគ្គិសនីសៀមរាប** សៀមរាប គឺជាតំបន់ទាក់ទាញភ្ញៀវទេសចរណ៍ និងមានទីតាំងស្ថិតនៅភាគពាយ័ព្យនៃប្រទេសកម្ពុជា។ ការផ្គត់ផ្គង់អគ្គិសនីនៅខេត្តសៀមរាប បានមកពីការផលិត ដោយរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់ខ្លួន និងនាំចូលថាមពលពីប្រទេសថៃឡង់ដ៍។

ប្រព័ន្ធអគ្គិសនីសៀមរាប សម្រាប់ឆ្នាំ ២០១៣ មានសមត្ថភាពផ្គត់ផ្គង់ ៥០,៥០ MW និងតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ៥៦,៧០ MW ។ ប្រភពថាមពលនៅក្នុងប្រព័ន្ធទាំងមូល ទទួលបានពីការនាំចូលពីប្រទេសថៃឡង់ដ៍តាមរយៈអនុស្ថានីយ ១១៥/២២ kV និងការផលិតដោយរោងចក្រផ្ទាល់ខ្លួនសរុបចំនួន ២៩៦,១០ GWh ។ ប្រវែងខ្សែបណ្ដាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្ដាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ៧៣៦,៩១ km ដែលបានផ្គត់ផ្គង់ជូនអតិថិជនគ្រប់ប្រភេទចំនួន ៣២.៧២៥ ។

**អគ្គិសនីខេត្តព្រះសីហនុ** ខេត្តព្រះសីហនុ គឺជាតំបន់ទេសចរណ៍ ដែលមានឆ្នេរសមុទ្រស្អាតជាប់ចំណាត់ថ្នាក់លេខ ១ ស្ថិតនៅភាគនិរតីនៃប្រទេសកម្ពុជា។ កន្លងមកប្រព័ន្ធអគ្គិសនីក្រុងព្រះសីហនុ ជាប្រព័ន្ធដាច់ដោយឡែកពីគេ និងទទួលការផ្គត់ផ្គង់ពីរោងចក្រអគ្គិសនីរបស់រោងចក្រផលិតថាមពលឯករាជ្យ និងរោងចក្រអគ្គិសនីកម្ពុជា ដែលមានអានុភាពសរុប ១៩,៦០ MW ។ ប៉ុន្តែក្នុងឆ្នាំ ២០១៣ ក្រោមគម្រោងអគ្គិសនីភាវូបនីយកម្មជនបទ ប្រព័ន្ធអគ្គិសនីខេត្តព្រះសីហនុ ត្រូវបានភ្ជាប់ និងផ្គត់ផ្គង់មួយផ្នែកពីប្រព័ន្ធអគ្គិសនីកំពត ដែលបាននាំចូលថាមពលពីប្រទេសវៀតណាមតាមរយៈបណ្ដាញ ២២ kV ។ ខ្សែបណ្ដាញនេះ បានធ្វើឲ្យអគ្គិសនី

ខេត្តព្រះសីហនុមានសមត្ថភាពផ្គត់ផ្គង់អគ្គិសនី ទៅអ្នកកាន់អាជ្ញាបណ្ណ និងតំបន់ជាច្រើនទៀត នៅក្រុងព្រះសីហនុ។ ថាមពលផលិតសរុបប្រចាំឆ្នាំមាន ១០៨,៣១ GWh ដែលតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ២៤,៨០ MW ហើយប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ៣០៤,៣៧ km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ១៣.១៤៦ ។

**អគ្គិសនីកំពង់ចាម** កំពង់ចាម ជាតំបន់ដែលសំបូរទៅដោយចំការកៅស៊ូ មានទីតាំងស្ថិតនៅភាគខាងកើតនៃប្រទេសកម្ពុជា។ ប្រព័ន្ធអគ្គិសនីកំពង់ចាម ជាប្រព័ន្ធនៅដាច់ដោយឡែក ដែលមួយផ្នែកត្រូវបានផ្គត់ផ្គង់ដោយរោងចក្រផលិតថាមពលឯករាជ្យ និងមួយផ្នែកទៀត ត្រូវបានផ្គត់ផ្គង់ដោយប្រព័ន្ធអគ្គិសនីដែលនាំចូលថាមពលពីប្រទេសវៀតណាម ។ ក្នុងឆ្នាំ២០១៣ ថាមពលទិញ និងនាំចូលសរុបប្រចាំឆ្នាំ ៨៦,៨៤ GWh អានុភាពតម្លើង ៩,១៨ MW ដែលតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ១៦,៨០ MW ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ១៤៩,៦៩ km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ១៣.០០៣។

**សាខាមេមត់ និងពញាក្រែក** ប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីសម្រាប់ស្រុកមេមត់ និងពញាក្រែក មានទីតាំងស្ថិតនៅខេត្តកំពង់ចាម និងប្រើប្រាស់ប្រព័ន្ធបណ្តាញតង់ស្យុងមធ្យម ២២ kV ។ ការផ្គត់ផ្គង់ថាមពលអគ្គិសនីទៅតំបន់ទាំងពីរនេះ ត្រូវបាននាំចូលពីប្រទេសវៀតណាម ចាប់ពីឆ្នាំ២០០២ ដែលមានអានុភាពផ្គត់ផ្គង់តាមកិច្ចសន្យា ១០ MW ក្នុងឆ្នាំ ២០១៣ ថាមពលនាំចូលទទួលបាន ៥៤,៨៦ GWh ព្រមទាំងប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ៩៣,៤១ km ដែលតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ១០,៤៥ MW និងបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ៨.១៧០ ។

**អគ្គិសនីបាត់ដំបង** បាត់ដំបង ជាតំបន់ដែលផលិតអង្ករជាប់ចំណាត់ថ្នាក់លេខ១ មានទីតាំងស្ថិតនៅភាគពាយ័ព្យនៃប្រទេសកម្ពុជា។ ខ្សែបញ្ជូន ១១៥ kV សម្រាប់នាំចូលថាមពលអគ្គិសនីពីប្រទេសថៃឡង់ដ៏ត្រូវបានតភ្ជាប់ជាមួយប្រព័ន្ធបញ្ជូនអគ្គិសនីសៀមរាប និងបន្ទាយមានជ័យ។ ការផ្គត់ផ្គង់ថាមពលអគ្គិសនីក្នុងខេត្តបាត់ដំបង បានមកពីការនាំចូលពីប្រទេសថៃឡង់ដ៏ និងការផលិតថាមពលពីរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់។ ប្រព័ន្ធអគ្គិសនីបាត់ដំបង មានសមត្ថភាពផ្គត់ផ្គង់ ២១,៦០ MW និងមានថាមពលផលិតសរុបប្រចាំឆ្នាំប្រមាណ ១៣៣,៧៧ GWh ព្រមទាំងតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ២២,៧៨ MW ។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ៦៩១,៥៣ km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ៤០.៧៣៥ ។

**អគ្គិសនីបន្ទាយមានជ័យ និងសាខាមង្គលបូរី** បន្ទាយមានជ័យមានទីតាំងស្ថិតនៅភាគពាយ័ព្យនៃប្រទេសកម្ពុជា ។ ការផ្គត់ផ្គង់ថាមពលអគ្គិសនីក្នុងខេត្តបន្ទាយមានជ័យ បានពីការនាំចូលពីប្រទេសថៃឡង់ដ៏ និងការផលិតថាមពលពីរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់ ។ សមត្ថភាពផ្គត់ផ្គង់របស់ប្រព័ន្ធអគ្គិសនីនេះមាន ២៣,០៨ MW ។ នៅឆ្នាំ ២០១៣ ថាមពលផលិតសរុបគឺ ៥១,១៩ GWh ដែលតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ១០,៨១ MW ។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ២៥៦,១៣ km និងបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ១៨.០២២ ។

**អគ្គិសនីស្ទឹងត្រែង** ស្ទឹងត្រែង គឺជាខេត្តដាច់ស្រយាលមួយ និងមានប្រជាជនរស់នៅរង្វើលៗ ឃ្លាតៗពីគ្នាដែលស្ថិតនៅភាគឦសាននៃប្រទេសកម្ពុជា ។ ប្រព័ន្ធអគ្គិសនីក្រុងស្ទឹងត្រែង បានតភ្ជាប់ទៅប្រព័ន្ធអគ្គិសនីប្រទេសឡាវ តាមរយៈតង់ស្យុង ២២ kV តាំងពីឆ្នាំ ២០១០។ សមត្ថភាពផ្គត់ផ្គង់សរុបគឺ ៥,៦៤ MW ( ដែល ១,៦៤ MW ផ្គត់ផ្គង់ដោយរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់ និង ៤ MW នាំចូលពីប្រទេសឡាវ ) ។ ក្នុងឆ្នាំ២០១៣ តម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ៣,៨០ MW និងថាមពលផលិតសរុប ១០,៥៨ GWh ។

ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ២០២,៩៣ km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ៩.៦៦៨ ។

**អគ្គិសនីរតនគិរី** រតនគិរី ស្ថិតនៅជាប់ព្រំដែនខ្ពង់រាបកណ្តាល នៃប្រទេសវៀតណាម និងប្រទេសឡាវ។ ប្រព័ន្ធអគ្គិសនីរតនគិរី មានអានុភាពតម្លើង ០,៩៦ MW ពីរោងចក្រវារីអគ្គិសនី របស់អគ្គិសនីកម្ពុជាផ្ទាល់ និង ៧,៥០ MW នាំចូលពីប្រទេសវៀតណាម តាមរយៈខ្សែបញ្ជូនរង តង់ស្យុង ៣៥ kV ។ នៅឆ្នាំ ២០១៣ តម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ៩,១៧ MW ថាមពលផលិត និងនាំចូលសរុបប្រចាំឆ្នាំប្រមាណ ២២,៧៣ GWh ។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ១៣៨,៧០ km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ៩.២៣៣។

**អគ្គិសនីតាកែវ និងសាខាអង្គតាសោម** តាកែវ មានទីតាំងស្ថិតនៅតំបន់វាលរាបភាគខាងត្បូងនៃប្រទេសកម្ពុជា។ ខ្សែបញ្ជូនតង់ស្យុង ២៣០ kV ចេញពីប្រទេសវៀតណាម និងអនុស្ថានីយតាកែវ ត្រូវបានដាក់ឲ្យដំណើរការនៅថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៩ ដើម្បីនាំចូលថាមពលពីប្រទេសវៀតណាម។ អគ្គិសនីតាកែវមានរោងចក្រអគ្គិសនីរបស់ខ្លួនដើម្បីទុកបម្រុង ដែលមានអានុភាពតម្លើង ១,៥៦ MW និង ១៦ MW នាំចូលពីប្រទេសវៀតណាម ។ នៅឆ្នាំ២០១៣ តម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ៨,៧៧ MW ដែលប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ៣៦៧,៩៦ km ថាមពលផលិត និងនាំចូលសរុបប្រចាំឆ្នាំ ៣៩,៣៩ GWh ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ១៣.០៨១ ។

**អគ្គិសនីកំពត** កំពត មានទីតាំងស្ថិតនៅភាគខាងត្បូងនៃប្រទេសកម្ពុជា។ រោងចក្រអគ្គិសនីកំពត មានអានុភាពតម្លើង ៣,០៨ MW និងនាំចូលថាមពលពីប្រទេសវៀតណាម តាមរយៈខ្សែបណ្តាញតង់ស្យុង ២២ kV ឆ្លងកាត់កំពង់ត្រាច សម្រាប់ផ្គត់ផ្គង់ឲ្យក្រុងកំពត ។ នៅឆ្នាំ ២០១៣ ថាមពលផលិត ដែលផ្គត់ផ្គង់ដោយរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់ និងការនាំចូលមានចំនួនសរុប ៣១,៨៤ GWh ហើយតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ៥,៩២ MW ។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ៣៣៨,៨៩ km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ១០.៥៥៩។

**សាខាកំពង់ត្រាច** ប្រព័ន្ធអគ្គិសនីកំពង់ត្រាច ស្ថិតនៅក្នុងខេត្តកំពត និងនាំចូលអគ្គិសនីពីប្រទេសវៀតណាម តាំងពីឆ្នាំ២០០២ ។ នៅឆ្នាំ២០១៣ អានុភាពជាវតាមកិច្ចសន្យាគឺ ១០ MW ហើយប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ៧៥,៦៥ km មានថាមពលនាំចូលសរុប ១៦,៦៤ GWh និងតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ៣,៣៨ MW ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ៣.៤៩៩។

**អគ្គិសនីព្រៃវែង** ព្រៃវែង មានទីតាំងស្ថិតនៅភាគអាគ្នេយ៍ នៃប្រទេសកម្ពុជា។ ប្រព័ន្ធអគ្គិសនីក្រុងព្រៃវែងមានអានុភាពតម្លើងសរុប ៤,៩៤ MW ដែលបានមកពីរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់ និងទទួលការផ្គត់ផ្គង់ពីខ្សែបណ្តាញអគ្គិសនី ដែលនាំចូលថាមពលពីប្រទេសវៀតណាម។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ៤៧៣,៩៦ km និងតម្រូវការអានុភាពអតិបរមា ២,៧៣ MW ព្រមទាំងថាមពលផលិត និងនាំចូលក្នុងឆ្នាំ២០១៣ ប្រមាណ ១៥,៣៨ GWh ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ៥.៧៩០ ។

**អគ្គិសនីស្វាយរៀង** ស្វាយរៀង មានទីតាំងស្ថិតនៅភាគអាគ្នេយ៍នៃប្រទេសកម្ពុជា។ អគ្គិសនីស្វាយរៀង ត្រូវបានផ្គត់ផ្គង់ដោយការនាំចូលថាមពលពីប្រទេសវៀតណាម និងពីរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់ អានុភាពផលិតសរុប ៨,៣០ MW ។ នៅឆ្នាំ ២០១៣ ថាមពលនាំចូល និងផលិតដោយរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់គឺ ៣៣,២១ GWh ដែលមានតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ៦,៦៧ MW ។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ៩១៩,០៩ km ព្រមទាំងបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ១២.៤៧៤។

**សាខាបាវិត** ប្រព័ន្ធអគ្គិសនីបាវិត ស្ថិតនៅខេត្តស្វាយរៀង និងទទួលការផ្គត់ផ្គង់ថាមពលតាមរយៈការនាំចូលពីប្រទេសវៀតណាម។ នៅឆ្នាំ២០១៣ អានុភាពនាំចូលពីប្រទេសវៀតណាមប្រមាណ ១៦ MW និងមានតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ១៦,១៥ MW ហើយថាមពលនាំចូលមាន ៨៧,៥៧ GWh និងប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ១៨៥,៥៦ km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ៣.១៧៤ ។

**អគ្គិសនីមណ្ឌលគិរី** អគ្គិសនីមណ្ឌលគិរី ត្រូវបានផ្ទេរមកនៅក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជានៅឆ្នាំ ២០១០។ អានុភាពតម្លើង ៣៧០ kW ផលិតដោយរោងចក្រវារីអគ្គិសនី អានុភាពផលិតដោយម៉ាស៊ីនឌីយ៉ែសែល ៣០០ kW និងអានុភាពនាំចូលពីប្រទេសវៀតណាមប្រមាណ ១ MW ។ ក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជានៅឆ្នាំ២០១៣ ថាមពលផលិត និងនាំចូលសរុប ៣,៣៩ GWh និងតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ០,៨៦ MW ។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ១២០,៣៩ km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ២.០៧០។

**សាខាកែវសីមា** អគ្គិសនីកែវសីមា ស្ថិតនៅក្នុងខេត្តមណ្ឌលគិរី។ ការផ្គត់ផ្គង់ថាមពល គឺតាមរយៈការនាំចូលពីប្រទេសវៀតណាម ដែលអានុភាពបញ្ចេញតាមកិច្ចសន្យា ០,៣៦ MW ។ ថាមពលនាំចូលគឺ ២,២១ GWh និងតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ០,៥៧ MW ។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ៧៧,៩១ km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ១.៣៣៧។

**អគ្គិសនីក្រចេះ** អគ្គិសនីក្រចេះ ត្រូវបានគ្រប់គ្រងដោយអគ្គិសនីកម្ពុជានៅឆ្នាំ ២០១១។ ប្រព័ន្ធអគ្គិសនីក្រចេះ ជាប្រព័ន្ធនៅដាច់ដោយឡែក ដែលផ្គត់ផ្គង់ដោយរោងចក្រផលិតថាមពលឯករាជ្យ ដែលមានអានុភាពតម្លើង ៣,២៧ MW ។ ក្រោមការគ្រប់គ្រងដោយអគ្គិសនីកម្ពុជានៅឆ្នាំ២០១៣ ថាមពលទិញ និងនាំចូលប្រចាំឆ្នាំ ១០,៤៩ GWh និងតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ២,៥៩ MW ។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ១៦០,១៤ km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ៥.៤០៤។

**សាខាស្នួល** ប្រព័ន្ធអគ្គិសនីស្នួល ស្ថិតនៅខេត្តក្រចេះ ។ ប្រព័ន្ធនេះ បានផ្គត់ផ្គង់ដោយការនាំចូលថាមពលពីប្រទេសវៀតណាមប្រមាណ ៤ MW ដោយមានថាមពលផលិតប្រចាំឆ្នាំ ៩,៣៥ GWh និងតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ១,៤៧ MW ។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ៣២,៦៩ km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ១.១៦៧។

**អគ្គិសនីកំពង់ស្ពឺ** នៅពាក់កណ្តាលឆ្នាំ ២០១២ សាខាកំពង់ស្ពឺ ត្រូវបានបង្កើតជាអង្គភាពខេត្ត ខណៈដែលសាខានេះ កាលពីពេលកន្លងមក បានស្ថិតក្រោមប្រព័ន្ធគ្រប់គ្រងអគ្គិសនីភ្នំពេញ។ អង្គភាពថ្មីនេះទទួលបន្ទុកគ្រប់គ្រងប្រព័ន្ធអគ្គិសនីក្នុងក្រុងកំពង់ស្ពឺ និងតំបន់តាមបណ្តោយផ្លូវជាតិលេខ៤ ដែលចែកចាយថាមពលដល់អនុស្ថានីយកំពង់ស្ពឺ។ ថាមពលដែលលក់ប្រចាំឆ្នាំគឺ ៥២,៤៨ GWh មានប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ៨០៥,៥៨ km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ១០.៨២៨ ។

## តារាងទី ២ : អានុភាពតម្លើង និងអានុភាពបញ្ចេញពីប្រភពរោងចក្រ និងការនាំចូល (MW)

| ឆ្នាំ | | | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|---|---|---|
| ទីតាំង | | អានុភាព | | | | | | |
| ភ្នំពេញ | | តម្លើង | ២៤៧,២៨ | ៤៥៣,៤៨ | ៤២៩,៤៨ | ៤២៩,៤៨ | ៦៣៣,៩០ | ១.២១៩,៥៨ |
| | | បញ្ចេញ | ២១៧,៤៩ | ៣១៧,៤៩ | ៣១៧,៨៩ | ៣៣២,៨៩ | ៥៧១,២៩ | ៩៦៨,១៩ |
| អគ្គិសនីកម្ពុជា | | តម្លើង | ៤៥,៦០ | ៤៥,៦០ | ៤៤ | ៤៤ | ៤៤ | ៤៤ |
| | | បញ្ចេញ | ៤២,៦០ | ៤២,៦០ | ៤១ | ៤១ | ៤១ | ៤១ |
| CUPL | IPP | តម្លើង | ៣៧,១០ | ៣៧,១០ | ៣៧,១០ | ៣៧,១០ | ៣៧,១០ | ៣៧,១០ |
| | | បញ្ចេញ | ៣១,៩៩ | ៣១,៩៩ | ៣១,៩៩ | ៣១,៩៩ | ៣១,៩៩ | ៣១,៩៩ |
| គិរីរម្យ ១ | IPP | តម្លើង | ១២ | ១២ | ១២ | ១២ | ១២ | ១២ |
| | | បញ្ចេញ | ១១ | ១១ | ១១ | ១១ | ១១ | ១១ |
| គិរីរម្យ ៣ | IPP | តម្លើង | - | - | - | - | ១៨ | ១៨ |
| | | បញ្ចេញ | - | - | - | - | ១៨ | ១៨ |
| កំចាយ | IPP | តម្លើង | - | - | - | - | ១៩៤,១០ | ១៩៤,១០ |
| | | បញ្ចេញ | - | - | - | - | ១៩៤,១០ | ១៩៤,១០ |
| អាតៃ | IPP | តម្លើង | - | - | - | - | - | ១២០ |
| | | បញ្ចេញ | - | - | - | - | - | ១២០ |
| ឫស្សីជ្រុំក្រោម | IPP | តម្លើង | - | - | - | - | - | ៣៣៨ |
| | | បញ្ចេញ | - | - | - | - | - | ១៦៩ |
| CEL | IPP | តម្លើង | - | - | - | - | - | ១២០ |
| | | បញ្ចេញ | - | - | - | - | - | ១០០ |
| KEP | IPP | តម្លើង | ៤៩,២០ | ៤៩,២០ | ៤៩,២០ | ៤៩,២០ | ៤៩,២០ | ៤៩,២០ |
| | | បញ្ចេញ | ៤៥ | ៤៥ | ៤៥ | ៤៥ | ៤៣,២០ | ៤៣,២០ |
| CITY Power | IPP | តម្លើង | ៧,៦៨ | ៧,៦៨ | ៧,៦៨ | ៧,៦៨ | - | ៧,៦៨ |
| | | បញ្ចេញ | ៦,៩០ | ៦,៩០ | ៦,៩០ | ៦,៩០ | - | ៦,៩០ |
| CEP | IPP | តម្លើង | ៤៩,២០ | ៤៩,២០ | ៤៩,២០ | ៤៩,២០ | ៤៩,២០ | ៤៩,២០ |
| | | បញ្ចេញ | ៤៥ | ៤៥ | ៤៥ | ៤៥ | ៤៥ | ៤៥ |
| COLBEN | IPP | តម្លើង | ១៤ | ២០,២០ | ២០,២០ | ២០,២០ | ២០,២០ | ២០,២០ |
| | | បញ្ចេញ | ១០ | ១០ | ១០ | ១០ | ១០ | ១០ |
| TH | IPP | តម្លើង | ១០ | ១០ | - | - | - | - |
| | | បញ្ចេញ | ៨ | ៨ | - | - | - | - |
| COLBEN PPSEZ | IPP | តម្លើង | ១២,៤០ | ១២,៤០ | - | - | - | - |
| | | បញ្ចេញ | ១០ | ១០ | - | - | - | - |
| សុវណ្ណភូមិ | IPP | តម្លើង | ១០,១០ | ១០,១០ | ១០,១០ | ១០,១០ | ១០,១០ | ១០,១០ |
| | | បញ្ចេញ | ៧ | ៧ | ៧ | ៧ | ៧ | ៨ |

## តារាងទី ២ : អានុភាពតម្លើង និងអានុភាពបញ្ចេញពីប្រភពរោងចក្រ និងការនាំចូល (MW) (ត)

| ឆ្នាំ | | | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|---|---|---|
| ទីតាំង | | អានុភាព | | | | | | |
| West PP (នាំចូល VN) | IMP | PPA | - | ២០០ | ២០០ | ២០០ | ២០០ | ២០០ |
| | | បញ្ចេញ | - | ១០០ | ១២០ | ១៣៥ | ១៧០ | ១៧០ |
| អគ្គិសនី ខេត្ត-ក្រុង | | តម្លើង | ១៥៤,២៤ | ១៦៣,០៤ | ១៧៤,៦៧ | ១៨៧,០៩ | ២១៤,៨៨ | ២១៧,២៤ |
| | | បញ្ចេញ | ១៥០,០៦ | ១៥៦,២៦ | ១៦៧,៨៩ | ១៧៨,៩៩ | ២០៦,៦៩ | ២០៩,៨៩ |
| អគ្គិសនី សៀមរាប | IPP | តម្លើង | - | - | - | - | - | - |
| | | បញ្ចេញ | - | - | - | - | - | - |
| | EDC | តម្លើង | ១០,៥០ | ១០,៥០ | ១០,៥០ | ១០,៥០ | ១០,៥០ | ១០,៥០ |
| | | បញ្ចេញ | ១០,៥០ | ១០,៥០ | ១០,៥០ | ១០,៥០ | ១០,៥០ | ១០,៥០ |
| | IMP | PPA | ៨០ | ៨០ | ៨០ | ៨០ | ៨០ | ៨០ |
| | | បញ្ចេញ | ៨០ | ៨០ | ៨០ | ៨០ | ៨០ | ៨០ |
| អគ្គិសនី ខេត្តព្រះសីហនុ | EDC | តម្លើង | ៧,៨០ | ៥,៦០ | ៥,៦០ | ៥,៦០ | ៥,៦០ | ៥,៦០ |
| | | បញ្ចេញ | ៦,២០ | ៥ | ៥ | ៥ | ៥ | ៥ |
| | IPP | តម្លើង | ៨ | ១៤ | ១៤ | ១៤ | ១៤ | ១៤ |
| | | បញ្ចេញ | ៧ | ១០ | ១០ | ១០ | ១០ | ១០ |
| អគ្គិសនី កំពង់ចាម | IPP | តម្លើង | ៧,៦៨ | ៧,៦៨ | ៧,៦៨ | ៧,៦៨ | ៧,៦៨ | ៧,៦៨ |
| | | បញ្ចេញ | ៧ | ៧ | ៧ | ៧ | ៧ | ៧ |
| | IMP | PPA | - | - | - | ១,៥០ | ១,៥០ | ១,៥០ |
| | | បញ្ចេញ | - | - | - | ១,៥០ | ១,៥០ | ១,៥០ |
| សាខា ពញាក្រែក | IMP | តម្លើង | ៥ | ៥ | ៥ | ៥ | ៥ | ៥ |
| | | បញ្ចេញ | ៥ | ៥ | ៥ | ៥ | ៥ | ៥ |
| សាខា មេមត់ | IMP | តម្លើង | ៥ | ៥ | ៥ | ៥ | ៥ | ៥ |
| | | បញ្ចេញ | ៥ | ៥ | ៥ | ៥ | ៥ | ៥ |
| អគ្គិសនី តាកែវ | EDC | តម្លើង | ១,៥៦ | ១,៥៦ | ១,៥៦ | ១,៥៦ | ១,៥៦ | ១,៥៦ |
| | | បញ្ចេញ | ១,៥០ | ១,៥០ | ១,៥០ | ១,៥០ | ១,៥០ | ១,៥០ |
| | IMP | តម្លើង | - | ៣ | ៣ | ៤ | ១៦ | ១៦ |
| | | បញ្ចេញ | - | ៣ | ៣ | ៤ | ១៦ | ១៦ |
| អគ្គិសនី បាត់ដំបង | EDC | តម្លើង | ១,៦០ | ១,៦០ | ៣,២០ | ៣,២០ | ៣,២០ | ១,៦០ |
| | | បញ្ចេញ | ០,៨០ | ០,៨០ | ២,៨០ | ២,៨០ | ២,៨០ | ១,៦០ |
| | IPP | តម្លើង | - | - | - | - | - | - |
| | | បញ្ចេញ | - | - | - | - | - | - |
| | IMP | PPA | ២០ | ២០ | ២០ | ២០ | ២០ | ២០ |
| | | បញ្ចេញ | ២០ | ២០ | ២០ | ២០ | ២០ | ២០ |

**តារាងទី ២ : អានុភាពតម្លើង និងអានុភាពបញ្ចេញពីប្រភពរោងចក្រ និងការនាំចូល (MW) (ត)**

| ឆ្នាំ | | | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|---|---|---|
| ទីតាំង | | អានុភាព | | | | | | |
| អគ្គិសនីកំពត | EDC | តម្លើង | ៣,០៨ | ៣,០៨ | ៣,០៨ | ៣,០៨ | ៣,០៨ | ៣,០៨ |
| | | បញ្ចេញ | ៣ | ៣ | ៣ | ៣ | ៣ | ៣ |
| សាខាកំពង់ត្រាច | IMP | តម្លើង | ៣ | ៣ | ១០ | ១០ | ១០ | ១០ |
| | | បញ្ចេញ | ៣ | ៣ | ១០ | ១០ | ១០ | ១០ |
| អគ្គិសនីព្រៃវែង | EDC | តម្លើង | ១,៦៤ | ១,៦៤ | ១,៦៤ | ១,៦៤ | ១,៦៤ | ១,៦៤ |
| | | បញ្ចេញ | ១,៥០ | ១,៥០ | ១,៥០ | ១,៥០ | ១,៥០ | ១,៥០ |
| | IMP | តម្លើង | - | ០,៨០ | ០,៨០ | ០,៨០ | ០,៨០ | ៣,៣០ |
| | | បញ្ចេញ | - | ០,៨០ | ០,៨០ | ០,៨០ | ០,៨០ | ៣,៣០ |
| អគ្គិសនីបន្ទាយមានជ័យ | EDC | តម្លើង | ៣,០៨ | ៣,០៨ | ៣,០៨ | ៣,០៨ | ៣,០៨ | ៣,០៨ |
| | | បញ្ចេញ | ៣ | ៣ | ៣ | ៣ | ៣ | ៣ |
| | IMP | PPA | ២០ | ២០ | ២០ | ២០ | ២០ | ២០ |
| | | បញ្ចេញ | ២០ | ២០ | ២០ | ២០ | ២០ | ២០ |
| អគ្គិសនីស្ទឹងត្រែង | EDC | តម្លើង | ១,៦៤ | ១,៦៤ | ១,៦៤ | ១,៦៤ | ១,៦៤ | ១,៦៤ |
| | | បញ្ចេញ | ១,៥០ | ១,៥០ | ១,៥០ | ១,៥០ | ១,៥០ | ១,៥០ |
| | IMP | តម្លើង | - | - | ២ | ២ | ៤ | ៤ |
| | | បញ្ចេញ | - | - | ២ | ២ | ៤ | ៤ |
| អគ្គិសនីរតនគិរី | IPP | តម្លើង | ០,៨០ | ១,៦០ | ១,៦០ | ០,៨០ | - | - |
| | | បញ្ចេញ | ០,៨០ | ១,៤០ | ១,៤០ | ០,៨០ | - | - |
| | EDC | តម្លើង | ០,៩៦ | ០,៩៦ | ០,៩៦ | ០,៩៦ | ០,៩៦ | ០,៩៦ |
| | | បញ្ចេញ | ០,៩៦ | ០,៩៦ | ០,៩៦ | ០,៩៦ | ០,៩៦ | ០,៩៦ |
| | IMP | តម្លើង | - | - | - | ៧ | ៧ | ៧,៥០ |
| | | បញ្ចេញ | - | - | - | ៧ | ៧ | ៧,៥០ |
| អគ្គិសនីស្វាយរៀង | EDC | តម្លើង | ០,៨០ | ០,៨០ | ០,៨០ | ០,៨០ | ០,៨០ | ០,៨០ |
| | | បញ្ចេញ | ០,៨០ | ០,៨០ | ០,៨០ | ០,៨០ | ០,៨០ | ០,៨០ |
| | IMP | តម្លើង | ៧,៥០ | ៧,៥០ | ៧,៥០ | ៧,៥០ | ៧ | ៧,៥០ |
| | | បញ្ចេញ | ៧,៥០ | ៧,៥០ | ៧,៥០ | ៧,៥០ | ៧ | ៧,៥០ |
| សាខាបាវិត | IMP | តម្លើង | ៥ | ៥ | ៥ | ៥ | ១៦ | ១៦ |
| | | បញ្ចេញ | ៥ | ៥ | ៥ | ៥ | ១៦ | ១៦ |

## តារាងទី ២ : អានុភាពតម្លើង និងអានុភាពបញ្ចេញពីប្រភពរោងចក្រ និងការនាំចូល (MW) (ត)

| ឆ្នាំ / ទីតាំង | | អានុភាព | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|---|---|---|
| អគ្គិសនីមណ្ឌលគិរី | EDC | តម្លើង | - | - | ០,៦៧ | ០,៦៧ | ០,៦៧ | ០,៦៧ |
| | | បញ្ចេញ | - | - | ០,៦៧ | ០,៦៧ | ០,៦៧ | ០,៦៧ |
| | IMP | តម្លើង | - | - | - | - | ១ | ១ |
| | | បញ្ចេញ | - | - | - | - | ១ | ១ |
| សាខាកែវសីមា | IMP | តម្លើង | - | - | ០,៣៦ | ០,៣៦ | ០,៣៦ | ០,៣៦ |
| | | បញ្ចេញ | - | - | ០,៣៦ | ០,៣៦ | ០,៣៦ | ០,៣៦ |
| អគ្គិសនីក្រចេះ | EDC | តម្លើង | - | - | - | - | - | ០,៥៥ |
| | | បញ្ចេញ | - | - | - | - | - | ០,៥០ |
| | IPP | តម្លើង | - | - | - | ២,៧២ | ២,៧២ | ២,៧២ |
| | | បញ្ចេញ | - | - | - | ១,២០ | ១,២០ | ១,២០ |
| សាខាស្នួល | IMP | តម្លើង | - | - | - | ១ | ៤ | ៤ |
| | | បញ្ចេញ | - | - | - | ១ | ៤ | ៤ |
| សរុប | | តម្លើង | ៤០១,៥២ | ៦១៦,៥២ | ៦០៤,១៥ | ៦១៦,៥៧ | ៨៤៨,៦៩ | ១.៤៣៦,៨២ |
| | | បញ្ចេញ | ៣៦៧,៥៥ | ៤៧៣,៧៥ | ៤៨៥,៧៨ | ៥១១,៨៨ | ៧៧៧,៩៨ | ១.១៧៨,០៨ |
| ជាភាគរយ , % | | | ៩១,៥៤% | ៧៦,៨៤% | ៨០,៤១% | ៨៣,០២% | ៩១,៦៧% | ៨១,៩៩% |




រូបភាពទី ១ : អានុភាពតម្លើងនៅឆ្នាំ ២០១៣




រូបភាព : អានុភាពបញ្ចេញនៅឆ្នាំ ២០១៣

## តារាងទី ៣ : ថាមពលផលិតពីប្រភពផលិតថាមពលចម្បង និងការនាំចូល (GWh)

| ឆ្នាំ / ទីតាំង | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|---|
| បណ្ដាញជាតិ | ១.៥៣៤,៩៧ | ១.៦៩២,៥៤ | ២.០៩៨,២១ | ២.៣៨៩,៤២ | ៣.០៨១,៥០ | ៤.០៦៣,៣៤ |
| អគ្គិសនីកម្ពុជា | ១៤៣,៨៥ | ៨២,៨៦ | ៣៣,០៨ | ៤៨,៥២ | ៥៨,២៨ | ៨៤,៨២ |
| CUPL | ២៥៨,៧១ | ១៨២,២២ | ១២០,២១ | ១៣៣,៤១ | ១៣២,១៤ | ៧៣,១៣ |
| Jupiter | - | - | - | - | - | - |
| គិរីរម្យ ១ | ៤៣,៣២ | ៤៤,៤១ | ២៤,២១ | ៣៨,២៥ | ២៩,២១ | ៤៤,៥៧ |
| កំចាយ | - | - | - | - | ៣៩៦,៣៨ | ៤៦៣,២៧ |
| គិរីរម្យ ៣ | - | - | - | - | ៨៦,៤០ | ៩០,៣៩ |
| អាតៃ | - | - | - | - | - | ២៦៧,០៦ |
| ឫស្សីជ្រុំក្រោម | - | - | - | - | - | ១៣៨,១៥ |
| T.H | ៣៤,៥០ | ១៧,៣១ | - | - | - | - |
| KEP | ៣១៧,៨៥ | ២៥៦,២៥ | ២៣០,៣៨ | ២៣១,៩០ | ១៩៦,៩៥ | ១៣៩,៦៧ |
| City Power | ៤១,៨២ | ៣៤,១១ | ១៨,២៣ | ២៥,២៦ | ១៥,៧៩ | ១៣,១៤ |
| CEP | ៣២៥,៨៨ | ២៦៩,៤៨ | ២៤៧,២៩ | ២២៧,៧០ | ២០៩,៤៦ | ១៤៣,៧៣ |
| COLBEN | ៤៦,៤៥ | ៥៣,២៤ | ៣៥,៨០ | ៣៤,១៧ | ៣១,០៧ | ១៩,១៥ |
| S.L Garment | ៤,៤១ | ៥,៧៦ | ៤,០៥ | ១១,៨៦ | ១០,១៧ | ៥,៥២ |
| COLBEN PPSEZ | ៣៥,៦៦ | ៤៥,០៦ | - | - | - | - |
| សុវណ្ណភូមិ | ២៣,៣៦ | ២៨,០៣ | ៣២,០៧ | ៤៦,៥០ | ៣៧,៤២ | ២៩,៧៥ |
| CEL | - | - | - | - | - | ១៣៩ |

## តារាងទី ៣ : ថាមពលផលិតពីប្រភពពោងចក្រ និងការនាំចូល (GWh) (ត)

| ឆ្នាំ / ទីតាំង | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|---|
| ថៃ | - | - | - | - | ៧៦,១៦ | ៩១៦,៩៧ |
| វៀតណាម | - | ៣៥៧,២១ | ៩៥៤,៥៥ | ១.១២០,៩៦ | ១.១៩៨,៩៦ | ១.៣២៩,១២ |
| PP Sugar | - | - | - | - | ១,៣២ | ០,៦៥ |
| សៀមរាប | ១៣៦,៩០ | ១៦៥,២០ | ១៩៣,៩៨ | ២១៤,១៥ | ២៦៨,៤៣ | ២៩៦,១០ |
| ព្រះសីហនុ | ៤៦,៧៣ | ៥១,១៦ | ៦៤,៩៦ | ៧៦,២២ | ៩០,០២ | ៦៦,៥០ |
| កំពង់ចាម | ១៥,៥៤ | ២៥,២៧ | ៣៤,៩៥ | ៣៨,៤៦ | ៥៧,០៨ | ៤៦,៤៥ |
| តាកែវ | ៥,៧៥ | ៧,៣៩ | ៩,២៨ | ១៣,១១ | ២៥,៧២ | ៣៩,៣៩ |
| បាត់ដំបង | ៣២,២៦ | ៣៨,២៥ | ៤៩,៧៣ | ៦៧,៨៣ | ១០៥,៩៩ | ១៣៣,៧៧ |
| កំពត | ៧,៨០ | ១០,១៧ | ២០,៨២ | ៣២,៧៥ | ១៤,៨១ | ៣១,៨៥ |
| បន្ទាយមានជ័យ | ១៤,១៨ | ១៩,១៦ | ២៤,៦៣ | ២៨,៣៧ | ៤០,១៣ | ៥១,១៩ |
| **ក្រៅបណ្ដាញជាតិ** | **៩០,៤៥** | **១២៥,៣១** | **១៤៤,២៩** | **១៧៤,៦៥** | **២២៨,៥៤** | **២៦៦,៣៣** |
| ពញាក្រែក | ១៨,៣៧ | ២៦,៩២ | ២៥,៩៨ | ៣២,២៧ | ៣៩,៩៤ | ៣៩,១៩ |
| មេមត់ | ៩,១៩ | ១០,៥៦ | ១០,៤០ | ១១,២៦ | ១៤,០៣ | ១៥,៦៧ |
| កំពង់ត្រាច | ៣,៩១ | ៥,៣៩ | ៨,៦៨ | ១៤,៩២ | ១៧,០៥ | ១៦,៦៤ |
| ព្រៃវែង | ២,៨០ | ៣,៣៦ | ៤,៦៨ | ៦,៦០ | ១១,៦៥ | ១៥,៣៨ |
| ស្ទឹងត្រែង | ៣,៥៣ | ៤,៣៩ | ៥,៨០ | ៦,៦៥ | ៩,០១ | ១០,៥៨ |
| រតនគិរី | ៥,៧៨ | ៦,៨១ | ៨,១៩ | ៩,៤៧ | ១៧,១៦ | ២២,៧៣ |
| ស្វាយរៀង | ៩,៤៥ | ១២,៩១ | ១៨,១៥ | ២៣,៨០ | ២៦,៩៩ | ៣៣,២១ |
| បារិត | ៣៧,៤២ | ៥៥,៣៧ | ៦០,៨៦ | ៥៩,៣៥ | ៧៤,០២ | ៨៧,៤៧ |
| មណ្ឌលគិរី | - | - | ១,១០ | ២,៣៤ | ២,៩៨ | ៣,៣៩ |
| កែវសីមា | - | - | ០,៤៥ | ១,០៣ | ១,៤៨ | ២,២១ |
| ក្រចេះ | - | - | - | ២,៣២ | ៦,៨៥ | ១០,៤៩ |
| ស្នួល | - | - | - | ៤,៦៨ | ៧,៣៨ | ៩,៣៥ |
| **សរុប** | **១.៦២៥,៤២** | **១.៨១៧,៨៥** | **២.២៤២,៤៩** | **២.៥៦៤,០៧** | **៣.៣១០,០៥** | **៤.៣២៩,៦៧** |

កំណត់សម្គាល់៖ ថាមពលផ្ទេរពីប្រតិបត្តិការរួមគ្នារវាងសាខា និងសាខាប្រមាណ ៦៩០,៦៨ GWh

### តារាងទី ៤ : ប្រភពថាមពលផលិតពីប្រភពរោងចក្រ និងការនាំចូលឆ្នាំ ២០១៣ (GWh)

| ទីតាំង | អគ្គិសនីកម្ពុជា | ឯកជន | ការនាំចូល | សរុប |
|---|---:|---:|---:|---:|
| បណ្ដាញជាតិ | ៤៤,១៤ | ១.៦២១,០៥ | ១.៧៥៧,៤៧ | ៣.៤២២,៦៦ |
| ភ្នំពេញ | ៣៥,៨៦ | ១.៥៦៧,១៩ | ១.៧៤៦,០៩ | ៣.៣៤៩,១៤ |
| សៀមរាប | ៤,៤០ | - | - | ៤,៤០ |
| ព្រះសីហនុ | ៣,៥៥ | ២១,៨០ | - | ២៥,៣៥ |
| កំពង់ចាម | - | ៣២,០៦ | - | ៣២,០៦ |
| តាកែវ | ០,០៣ | - | - | ០,០៣ |
| បាត់ដំបង | ០,០១ | - | - | ០,០១ |
| កំពត | ០,១៣ | - | ១១,៣៨ | ១១,៥១ |
| បន្ទាយមានជ័យ | ០,១៦ | - | - | ០,១៦ |
| ក្រៅបណ្ដាញ | ៥,៦៧ | ២,៨៨ | ២៥៧,៧៨ | ២៦៦,៣៣ |
| ពញាក្រែក | - | - | ៣៩,១៨ | ៣៩,១៨ |
| មេមត់ | - | - | ១៥,៦៧ | ១៥,៦៧ |
| កំពង់ត្រាច | - | - | ១៦,៦៤ | ១៦,៦៤ |
| ព្រៃវែង | ០,២៣ | - | ១៥,១៦ | ១៥,៣៩ |
| ស្ទឹងត្រែង | ០,០៦ | - | ១០,៥៣ | ១០,៥៩ |
| រតនគិរី | ៣,៤៧ | - | ១៩,២៦ | ២២,៧៣ |
| ស្វាយរៀង | ០,១២ | - | ៣៣,០៩ | ៣៣,២១ |
| បាវិត | - | - | ៨៧,៤៧ | ៨៧,៤៧ |
| មណ្ឌលគិរី | ១,៧៩ | - | ១,៦១ | ៣,៤០ |
| កែវសីមា | - | - | ២,២១ | ២,២១ |
| ក្រចេះ | - | ២,៨៨ | ៧,៦១ | ១០,៤៩ |
| ស្នួល | - | - | ៩,៣៥ | ៩,៣៥ |
| សរុប | ៤៩,៨១ | ១.៦២៣,៩៣ | ២.០១៥,២៥ | ៣.៦៨៨,៩៩ |




រូបភាពទី៣ : ថាមពលផលិតតាមប្រភព នៅឆ្នាំ ២០១៣

## តារាងទី ៥ : ការផលិតថាមពលតាមប្រភេទ អំឡុងឆ្នាំ ២០១៣ (GWh)

| ទីតាំង | ប្រេងឥន្ធនៈ | វារីអគ្គិសនី | ជីវម៉ាស់ | ធ្យូងថ្ម | នាំចូល | សរុប |
|---|---|---|---|---|---|---|
| បណ្ដាញជាតិ | ៤៧៣,៨១ | ១.០០៣,៤៥ | ៦,១៧ | ១៦៨,៧៥ | ១.៧៧០,៤៩ | ៣.៤២២,៦៦ |
| ភ្នំពេញ | ៤២៤,៦៨ | ១.០០៣,៤៥ | ៦,១៧ | ១៦៨,៧៥ | ១.៧៤៦,០៩ | ៣.៣៤៩,១៤ |
| សៀមរាប | ៤,៤០ | - | - | - | - | ៤,៤០ |
| ព្រះសីហនុ | ២៥,៣៥ | - | - | - | - | ២៥,៣៥ |
| កំពង់ចាម | ១៩,០៤ | - | - | - | ១៣,០២ | ៣២,០៦ |
| តាកែវ | ០,០៣ | - | - | - | - | ០,០៣ |
| បាត់ដំបង | ០,០១ | - | - | - | - | ០,០១ |
| កំពត | ០,១៣ | - | - | - | ១១,៣៨ | ១១,៥១ |
| បន្ទាយមានជ័យ | ០,១៦ | - | - | - | - | ០,១៦ |
| ក្រៅបណ្ដាញ | ៣,២៣ | ៥,១៣ | ០,១៨ | - | ២៥៧,៧៨ | ២៦៦,៣៣ |
| ពញាក្រែក | - | - | - | - | ៣៩,១៨ | ៣៩,១៨ |
| មេមត់ | - | - | - | - | ១៥,៦៧ | ១៥,៦៧ |
| កំពង់ត្រាច | - | - | - | - | ១៦,៦៤ | ១៦,៦៤ |
| ព្រៃវែង | ០,២៣ | - | - | - | ១៥,១៦ | ១៥,៣៩ |
| ស្ទឹងត្រែង | ០,០៦ | - | - | - | ១០,៥៣ | ១០,៥៩ |
| រតនគិរី | - | ៣,៤៧ | - | - | ១៩,២៦ | ២២,៧៣ |
| ស្វាយរៀង | ០,១២ | - | - | - | ៣៣,០៩ | ៣៣,២១ |
| បាវិត | - | - | - | - | ៨៧,៤៧ | ៨៧,៤៧ |
| មណ្ឌលគិរី | ០,១៣ | ១,៦៦ | - | - | ១,៦១ | ៣,៤០ |
| កែវសីមា | - | - | - | - | ២,២១ | ២,២១ |
| ក្រចេះ | ២,៦៩ | - | ០,១៨ | - | ៧,៦១ | ១០,៤៨ |
| ស្នួល | - | - | - | - | ៩,៣៥ | ៩,៣៥ |
| សរុប | ៤៧៧,០៤ | ១.០០៨,៥៨ | ៦,៣៥ | ១៦៨,៧៥ | ២.០២៨,២៧ | ៣.៦៨៨,៩៩ |




រូបភាពទី៤ : ការផលិតថាមពលតាមប្រភេទ នៅឆ្នាំ២០១៣

## តារាងទី ៦ : ប្រភពថាមពលផលិតក្នុងប្រព័ន្ធរបស់អគ្គិសនីកម្ពុជា អំឡុងឆ្នាំ ២០១៣ (GWh)

| ទីតាំង | អគ្គិសនីកម្ពុជា | ឯកជន | ការនាំចូល | ប្រតិបត្តិការរួមគ្នារវាង សាខា និងសាខា | សរុប |
|---|---:|---:|---:|---:|---:|
| បណ្តាញជាតិ | ៤៤,១៤ | ១.៦២១,០៥ | ១.៧៥៧,៤៧ | ៦៤០,៦៨ | ៤.០៥៣,៦៨ |
| ភ្នំពេញ | ៣៥,៨៦ | ១.៥៦៧,១៩ | ១.៧៤៦,០៩ | ៤៨,៩៦ | ៣.៣៩៨,១០ |
| សៀមរាប | ៤,៤០ | - | - | ២៩១,៧០ | ២៩៦,១០ |
| ព្រះសីហនុ | ៣,៥៥ | ២១,៨០ | - | ៤១,១៥ | ៦៦,៥០ |
| កំពង់ចាម | - | ៣២,០៦ | - | ១៤,៣៨ | ៤៦,៤៤ |
| តាកែវ | ០,០៣ | - | - | ៣៩,៣៦ | ៣៩,៣៩ |
| បាត់ដំបង | ០,០១ | - | - | ១៣៣,៧៦ | ១៣៣,៧៧ |
| កំពត | ០,១៣ | - | ១១,៣៨ | ២០,៣៣ | ៣១,៨៤ |
| បន្ទាយមានជ័យ | ០,១៦ | - | - | ៥១,០៣ | ៥១,១៩ |
| ក្រៅបណ្តាញ | ៥,៦៧ | ២,៨៨ | ២៥៧,៧៨ | - | ២៦៦,៣៣ |
| ពញាក្រែក | - | - | ៣៩,១៨ | - | ៣៩,១៨ |
| មេមត់ | - | - | ១៥,៦៧ | - | ១៥,៦៧ |
| កំពង់ត្រាច | - | - | ១៦,៦៤ | - | ១៦,៦៤ |
| ព្រៃវែង | ០,២៣ | - | ១៥,១៦ | - | ១៥,៣៩ |
| ស្ទឹងត្រែង | ០,០៦ | - | ១០,៥៣ | - | ១០,៥៩ |
| រតនគិរី | ៣,៤៧ | - | ១៩,២៦ | - | ២២,៧៣ |
| ស្វាយរៀង | ០,១២ | - | ៣៣,០៩ | - | ៣៣,២១ |
| បាវិត | - | - | ៨៧,៤៧ | - | ៨៧,៤៧ |
| មណ្ឌលគិរី | ១,៧៩ | - | ១,៦១ | - | ៣,៤០ |
| កែវសីមា | - | - | ២,២១ | - | ២,២១ |
| ក្រចេះ | - | ២,៨៨ | ៧,៦១ | - | ១០,៤៩ |
| ស្នួល | - | - | ៩,៣៥ | - | ៩,៣៥ |
| សរុប | ៤៩,៨១ | ១.៦២៣,៩៣ | ២.០១៥,២៥ | ៦៤០,៦៨ | ៤.៣២៩,៦៧ |

## តារាងទី ៧ : អានុភាពអតិបរមាប្រចាំឆ្នាំ (MW)

| ទីតាំង | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|---|
| ភ្នំពេញ | ២៣៩ | ២៤៩,១០ | ៣០០,២០ | ៣៤៩,៨០ | ៤១០ | ៤៩២,៥០ |
| សៀមរាប | ២៧,៥៩ | ២៩,៩៨ | ៣៤,៩៧ | ៣៩,០៧ | ៤៧,៣៦ | ៥៦,៧០ |
| ព្រះសីហនុ | ៩,៥០ | ១០,១៧ | ១៣,៤០ | ១៦,៤០ | ១៨,៥០ | ២៤,៨០ |
| កំពង់ចាម | ២,៤៨ | ៦,៨០ | ៧,៣០ | ៨,៤៥ | ១០,៤៥ | ១៦,៨០ |
| ពញាក្រែក | ៤,១០ | ៥,៥០ | ៥ | ៦,៥០ | ៦,៥០ | ៦,៥០ |
| មេមត់ | ៣,៨០ | ៣ | ៣ | ៣,៩៤ | ៣,៩៤ | ៤,៥០ |
| តាកែវ | ១,៣៩ | ២,២៦ | ២,៦៨ | ៤,៧៣ | ៦,៧០ | ៨,៧៧ |
| បាត់ដំបង | ៧,០២ | ៧,៩៨ | ១០,៤៥ | ១៦,៧៧ | ២០,៥៣ | ២២,៧៨ |
| កំពត | ១,៨៥ | ២,៣៦ | ៤,៥២ | ៥,៤៧ | ៥,៣៤ | ៥,៩០ |
| កំពង់ត្រាច | ០,៨៣ | ១,២០ | ២,១៣ | ២,៣៨ | ៣,១០ | ៣,៣៨ |
| ព្រៃវែង | ០,៨៣ | ០,៧៩ | ០,៩៣ | ១,៤៦ | ៣,១៥ | ២,៧៣ |
| បន្ទាយមានជ័យ | ៣,៩៤ | ៤,៣២ | ៥,៥១ | ៦,២៨ | ៨,៨២ | ១០,៨០ |
| ស្ទឹងត្រែង | ០,៩៨ | ១,០៨ | ១,៩៦ | ២,៣៧ | ៣,២២ | ៣,៨០ |
| រតនគិរី | ១,៦៨ | ១,៧៨ | ១,៩៤ | ២,២៤ | ៣,៦៩ | ៤,២០ |
| ស្វាយរៀង | ២,២៤ | ២,៨០ | ៣,៧០ | ៥,៤០ | ៥,៣០ | ៦,៦៧ |
| បាវិត | ៤,៨១ | ៩,៥០ | ១១ | ១១,២០ | ១៥,១០ | ១៥,៦០ |
| មណ្ឌលគិរី | - | - | ០,៤៦ | ០,៦២ | ០,៧០ | ០,៨៦ |
| កែវសីមា | - | - | - | - | ០,៣៨ | ០,៤៧ |
| ក្រចេះ | - | - | - | ២,០៨ | ១,១៨ | ២,៤៨ |
| ស្នួល | - | - | - | - | ១,៤៥ | ១,៤៨ |
| សរុប | ៣១២,០៤ | ៣៣៣,៦២ | ៤០៩,១៤ | ៤៨៤,៧៦ | ៥៧៥,៤១ | ៦៩១,៧២ |




រូបភាពទី៥ : ថាមពលផលិត, វិក្កយបត្រ និងប្រើប្រាស់ផ្ទាល់ខ្លួន
សម្រាប់ប្រព័ន្ធអគ្គិសនីភ្នំពេញពីឆ្នាំ២០០៨ - ២០១៣

## តារាងទី ៨ : ថាមពលលក់ (GWh)

| ទីតាំង | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|---|
| ភ្នំពេញ | ១.១៩២,៤៩ | ១.២៩៦,៥៣ | ១.៥៤០,២៥ | ១.៧៥២,៤០ | ២.២៦៥,៨៤ | ២.៥៣០,៥១ |
| សៀមរាប | ១១៧,២៩ | ១៤៥,១២ | ១៧០,៩៧ | ១៨៨,២៦ | ២៣៧,៣០ | ២៧០,០៤ |
| ព្រះសីហនុ | ៤១,២៦ | ៤៥,៤៨ | ៥៨,១៣ | ៦៨,៩៩ | ៧៩,៧៥ | ៩៥,៩២ |
| កំពង់ចាម | ១៣,២៦ | ២២,២៣ | ៣១,៣១ | ៣៤,៩៥ | ៥២,៣០ | ៤៤,១៣ |
| ពញាក្រែក | ១៧,៤៣ | ២៥,៥៦ | ២៤,៩៩ | ៣០,៦៣ | ៣៧,៩១ | ៣៧,១៣ |
| មេមត់ | ៨,៦៩ | ១០ | ៩,៨០ | ១០,៥៦ | ១៣,១២ | ១៤,៧៨ |
| តាកែវ | ៥,១១ | ៦,៦២ | ៨,៤១ | ១១,៩១ | ២៣,៥២ | ៣៦,៨៦ |
| បាត់ដំបង | ២៨,៥៩ | ៣៤,២៧ | ៤៥,៤១ | ៦២,៩៥ | ៩៨,៧២ | ១២៧,៤៦ |
| កំពត | ៧,០១ | ៩,០៩ | ១៥,២១ | ៣០,៦៧ | ៤៨,៥៩ | ២៩,៣៣ |
| កំពង់ត្រាច | ៣,៦៨ | ៥,១១ | ៨,២០ | ១៤,៦២ | ១៦,៧០ | ១៦,២៣ |
| ព្រៃវែង | ២,៤១ | ២,៨៨ | ៤,១៧ | ៥,៩៧ | ១០,៦៦ | ១៤,៣៩ |
| បន្ទាយមានជ័យ | ១២,៦៥ | ១៧,២៨ | ២២,៦២ | ២៦,១២ | ៣៦,៥០ | ៤៧,៣៤ |
| ស្ទឹងត្រែង | ៣,០៦ | ៤,១០ | ៤,៨៤ | ៥,៧៩ | ៨,០៨ | ៩,៥៩ |
| រតនគិរី | ៤,៩៩ | ៥,៧៧ | ៧,៥៣ | ៨,៦៧ | ១៥,៩៧ | ២១,៤៩ |
| ស្វាយរៀង | ៨,៥៣ | ១១,៨១ | ១៦,៥១ | ២៣,៣៣ | ២៣,៥៨ | ២៦,៣៧ |
| បារិត | ៣៤,៩៥ | ៥២,២២ | ៦១,៩៦ | ៥៥,០១ | ៧០,៦៥ | ៨៦,៨១ |
| មណ្ឌលគិរី | - | - | ០,៨៣ | ២,០៩ | ២,៦១ | ៣,០៥ |
| កែវសីមា | - | - | ០,៣៧ | ១,០១ | ១,៤៨ | ២,០៨ |
| ក្រចេះ | - | - | - | ២,២៥ | ៥,៩២ | ៩,៥៣ |
| ស្នួល | - | - | - | ២,១៦ | ៦,៤៩ | ៨,១៦ |
| កំពង់ស្ពឺ | - | - | - | ១៥,៩៧ | ៤២,២៧ | ៥២,៤៨ |
| សរុប | ១.៤៥១,៤២ | ១.៦៤៤,០៧ | ២.០៣១,៥០ | ២.៣៥៤,២៩ | ៣.០៩៧,៩៧ | ៣.៤៨៣,៦៦ |

កំណត់សម្គាល់៖ ថាមពលផ្ទេរពីប្រតិបត្តិការរួមគ្នារវាងសាខា និងសាខាប្រមាណ ៦៤០,៦៨ GWh




រូបភាពទី៦ : ថាមពលលក់តាមប្រភេទអតិថិជន សម្រាប់ប្រព័ន្ធអគ្គិសនីភ្នំពេញនៅឆ្នាំ ២០១៣

## តារាងទី ៩ : ថាមពលលក់ អំឡុងឆ្នាំ ២០១៣ (GWh)

| ទីតាំង | ថាមពលលក់ | គ្រោងចំណូលថ្លៃទិញថាមពល | ប្រតិបត្តិការរួមគ្នារវាងសាខា និងសាខា | សរុប |
|---|---|---|---|---|
| ភ្នំពេញ | ៣.១១១,១៩ | ៥២,៩៣ | (៦៣៣,៥៦) | ២.៥៣០,៥១ |
| សៀមរាប | ២៦៩,៥៥ | ០,៤៩ | - | ២៧០,០៤ |
| ព្រះសីហនុ | ៩៧,០៣ | (១,១២) | - | ៩៥,៩២ |
| កំពង់ចាម | ៤៣,៩៧ | ០,១៦ | - | ៤៤,១៣ |
| ពញាក្រែក | ៣៧,១២ | ០,០០ | - | ៣៧,១៣ |
| មេមត់ | ១៤,៦៥ | ០,១៣ | - | ១៤,៧៨ |
| តាកែវ | ៣៦,៧១ | ០,១៥ | - | ៣៦,៨៦ |
| បាត់ដំបង | ១២៧,៨៤ | (០,៣៩) | - | ១២៧,៤៦ |
| កំពត | ៣៦,៤៨ | (០,០៣) | (៧,១២) | ២៩,៣៣ |
| កំពង់ត្រាច | ១៦,២៣ | ០,០០ | - | ១៦,២៣ |
| ព្រៃវែង | ១៩,៣២ | ០,០៧ | - | ១៩,៣៩ |
| បន្ទាយមានជ័យ | ៤៧,៤០ | (០,០៦) | - | ៤៧,៣៤ |
| ស្ទឹងត្រែង | ៩,៥៨ | ០,០១ | - | ៩,៥៩ |
| រតនគិរី | ២១,៣២ | ០,១៨ | - | ២១,៤៩ |
| ស្វាយរៀង | ២៦,៤១ | (០,០៤) | - | ២៦,៣៧ |
| បារិត | ៨៦,៧៨ | ០,០៣ | - | ៨៦,៨១ |
| មណ្ឌលគិរី | ៣,០៥ | (០,០០) | - | ៣,០៥ |
| កែវសីមា | ២,០៧ | ០,០១ | - | ២,០៨ |
| ក្រចេះ | ៩,៤៥ | ០,០៨ | - | ៩,៥៣ |
| ស្ទួល | ៨,៥១ | (០,៣៤) | - | ៨,១៦ |
| កំពង់ស្ពឺ | ៥២,៨២ | (០,៣៣) | - | ៥២,៤៨ |
| សរុប | ៤.០៧២,៤២ | ៥១,៩២ | (៦៤០,៦៨) | ៣.៤៨៣,៦៦ |




រូបភាពទី៧ : ខ្សែកោងបន្ទុកប្រើប្រាស់ប្រចាំថ្ងៃជាមធ្យមពីឆ្នាំ២០០៨-២០១៣ ក្នុងរាជធានីភ្នំពេញ




រូបភាពទី៨ : ថាមពលបាត់បង់លើប្រព័ន្ធបណ្តាញអគ្គិសនីភ្នំពេញពីឆ្នាំ ២០០៨-២០១៣

## តារាងទី ១០ : ចំនួនអតិថិជន ពីឆ្នាំ ២០០៨-២០១៣

| ឆ្នាំ | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|---|
| ភ្នំពេញ | ២១១.៦៨០ | ២២៤.៥៩៣ | ២៤០.៩៩២ | ២៥៦.៦៤២ | ២៧៦.៣០៧ | ២៩៩.៧៧៤ |
| សៀមរាប | ១៦.៦០១ | ១៨.២២៩ | ១៩.៩៥១ | ២៦.១៥៦ | ២៨.៧៩១ | ៣២.៧២៥ |
| ព្រះសីហនុ | ៩.២៥៤ | ៩.៧៦៧ | ១០.៦៣៦ | ១១.៤៧២ | ១២.២៤៦ | ១៣.១៤៦ |
| កំពង់ចាម | ៧.១០១ | ៨.២២៥ | ១០.៤៧៨ | ១១.៧៣៩ | ១២.២៣៩ | ១៣.០០៣ |
| ពញាក្រែក | ២.០៩៥ | ២.២១០ | ២.៣៨៦ | ២.៥១៩ | ២.៦៩៤ | ២.៨៤៩ |
| មេមត់ | ៣.៦៤៤ | ៣.៧៣១ | ៤.០១៨ | ៤.២៨៥ | ៤.៩៩២ | ៥.៣២១ |
| តាកែវ | ៥.២៩២ | ៥.៦៣៨ | ៥.៩៨៧ | ៧.៦៨២ | ១១.២០១ | ១៣.០៨១ |
| បាត់ដំបង | ២០.០៩៣ | ២៣.៩០២ | ៣១.៥៧៥ | ៣២.៧៥៦ | ៣៨.៤៩៨ | ៤០.៧៣៥ |
| កំពត | ៦.០៧៩ | ៦.៣១៤ | ៧.១៧១ | ៧.៧៩៦ | ៩.៣៣២ | ១០.៥៥៩ |
| កំពង់ត្រាច | ២.១៥៩ | ២.២៨៧ | ២.៥១៥ | ២.៦៧៦ | ២.៨៣១ | ៣.៤៩៩ |
| ព្រៃវែង | ៣.៤៦០ | ៣.៥៥៤ | ៤.៤៤៧ | ៤.៧២៥ | ៥.៥៣៨ | ៥.៧៩០ |
| បន្ទាយមានជ័យ | ១៣.៤៦៤ | ១៣.៩៤១ | ១៤.៨១៦ | ១៦.០៨៥ | ១៧.២១៣ | ១៨.០២២ |
| ស្ទឹងត្រែង | ២.៣៧៨ | ២.៥០២ | ២.៦៣៦ | ៣.០៩០ | ៣.៥៦៣ | ៤.៦៦៨ |
| រតនគិរី | ២.៦៦៧ | ២.៧៧០ | ២.៩១០ | ៣.១៩៧ | ៣.៥៣៨ | ៤.២៣៣ |
| ស្វាយរៀង | ៧.៣២៥ | ៨.៥៦៥ | ១០.៧៩៥ | ១១.៣៩០ | ១០.២៩៨ | ១២.៤៧៤ |
| បាវិត | ២.២១៣ | ២.៣០១ | ២.៤៩៥ | ២.៥៦២ | ៤.៥១៨ | ៣.១៧៤ |
| មណ្ឌលគិរី | - | - | ១.៣២៨ | ១.៤៤៤ | ១.៧១៩ | ២.០៧០ |
| កែវសីមា | - | - | ៨៦១ | ៩៧៣ | ១.២០២ | ១.៣៣៧ |
| ក្រចេះ | - | - | - | ៣.៥៥២ | ៣.៦៣២ | ៤.៤០៤ |
| ស្នួល | - | - | - | ១.០៥១ | ១.០៩៤ | ១.១៦៧ |
| កំពង់ស្ពឺ | - | - | - | ៦.២៧៤ | ៩.៥៤៧ | ១០.៨២៨ |
| សរុប | ៣១៥.៥០៥ | ៣៣៨.៥២៩ | ៣៧៥.៩៩៧ | ៤១៨.០៦៦ | ៤៦០.៩៩៣ | ៥០២.៨៥៩ |




រូបភាពទី ៩ : ប្រភេទអតិថិជនក្នុងប្រព័ន្ធរបស់អគ្គិសនីកម្ពុជានៅឆ្នាំ ២០១៣

## បណ្ដាញខ្សែបញ្ជូន និងចែកចាយ

ខ្សែបញ្ជូន ១១៥ kV លើកទីមួយមានប្រវែង ២២,៧១ km ដែលតភ្ជាប់ពីអនុស្ថានីយចំនួនបី (អនុស្ថានីយទី១, អនុស្ថានីយទី២ និងអនុស្ថានីយទី៣) នៅក្នុងប្រព័ន្ធបណ្ដាញរាជធានីភ្នំពេញ បានផ្គត់ផ្គង់ថាមពលក្នុងឆ្នាំ ១៩៩៩។ នៅឆ្នាំ២០០២ មានខ្សែបញ្ជូន ១១៥ kV បន្ថែមមួយទៀត ដែលមានប្រវែង ១១១ km ត្រូវបានសាងសង់ ដើម្បីតភ្ជាប់ពីរោងចក្រវារីអគ្គិសនីគិរីរម្យ ១ មកកាន់អនុស្ថានីយទី១។ គោលបំណងដ៏ចម្បងនៃខ្សែបញ្ជូន ដែលមានតង់ស្យុង ១១៥ kV ព័ទ្ធជុំវិញរាជធានីភ្នំពេញ គឺដើម្បីផ្គត់ផ្គង់អគ្គិសនីឲ្យតំបន់រាជធានីភ្នំពេញ និងបង្កើនស្ថេរភាពលើប្រព័ន្ធផ្គត់ផ្គង់ថាមពលរាជធានីភ្នំពេញនេះ ដោយតភ្ជាប់ទៅវិញទៅមករវាងអនុស្ថានីយចំនួនបី។

ខេត្តចំនួនបី ស្ថិតនៅភាគពាយ័ព្យនៃប្រទេសកម្ពុជា មានខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាប បានផ្គត់ផ្គង់ថាមពលដោយខ្សែបញ្ជូន ១១៥ kV មានប្រវែង ១៨៥ km ដោយនាំចូលថាមពលពីប្រទេសថៃឡង់ដ៍ និងបានដាក់ឲ្យដំណើរការនៅចុងឆ្នាំ២០០៧។

នៅឆ្នាំ ២០០៩ ខ្សែបណ្ដាញបញ្ជូនតង់ស្យុង ២៣០ kV ជាលើកដំបូងក្នុងប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា ដែលមានប្រវែង ៩៧ km បានដាក់ឲ្យបម្រើសេវាកម្មផ្គត់ផ្គង់ ដែលនាំថាមពលពីប្រទេសវៀតណាម ដើម្បីផ្គត់ផ្គង់ថាមពលទៅអនុស្ថានីយតាកែវ និងអនុស្ថានីយខាងលិចភ្នំពេញ (អនុស្ថានីយទី៤)។ ប្រព័ន្ធខ្សែបញ្ជូន ១១៥ kV ដែលតភ្ជាប់អនុស្ថានីយខាងលិចភ្នំពេញ (អនុស្ថានីយទី៤) ទៅភ្ជាប់អនុស្ថានីយទី១ និងអនុស្ថានីយទី២ នៅរាជធានីភ្នំពេញ ត្រូវបានសាងសង់រួច និងដាក់ឲ្យដំណើរការក្នុងឆ្នាំនេះផងដែរ។

នៅឆ្នាំ ២០១១ ខ្សែបណ្ដាញបញ្ជូនតង់ស្យុង ២៣០ kV ដែលមានប្រវែង ៧៣ km ត្រូវបានពង្រីកចេញពីអនុស្ថានីយតាកែវ ទៅអនុស្ថានីយកំពត និងតភ្ជាប់ទៅរោងចក្រវារីអគ្គិសនីកំចាយ តាមខ្សែបញ្ជូន ២៣០ kV មួយទៀត ដែលមានប្រវែង ១១ km ក៏ត្រូវបានដាក់ឲ្យដំណើរការផងដែរនៅចុងឆ្នាំ ២០១១ នេះ។

ខ្សែបណ្ដាញបញ្ជូនតង់ស្យុងខ្ពស់ ២៣០ kV ពីរាជធានីភ្នំពេញទៅខេត្តបាត់ដំបង ត្រូវបានចាប់ផ្ដើមដាក់ឲ្យដំណើរការក្នុងខែមេសា ឆ្នាំ ២០១២ ដែលមានប្រវែង ៣០០ km និងខ្សែបញ្ជូនតង់ស្យុងខ្ពស់ ២៣០ kV មួយខ្សែទៀតពីអនុស្ថានីយអូរសោម (ខេត្តកោះកុង) ទៅអនុស្ថានីយខេត្តពោធិ៍សាត់ ស្ថិតក្រោមគម្រោង សាងសង់ ដំណើរការ និងផ្ទេរ (BOT) ដែលមានប្រវែង ១៣០ km កំពុងសាងសង់ ។ ការសាងសង់ខ្សែបណ្ដាញ ១១៥ kV ចេញពីអនុស្ថានីយ ២៣០/១១៥/២២ kV របស់ក្រុមហ៊ុន CPG ទៅភ្ជាប់ជាមួយនឹងអនុស្ថានីយ ១១៥ kV របស់ក្រុមហ៊ុន CPTL បានដាក់ឲ្យប្រើប្រាស់នៅថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០១២ ដែលផ្ដល់លទ្ធភាពឲ្យបណ្ដាញជាតិបញ្ជូន មានសមត្ថភាពពង្រីកវិសាលភាពគ្របដណ្ដប់ពីផ្នែកមួយនៃបណ្ដាញភាគខាងត្បូង (រាជធានីភ្នំពេញ ខេត្តកណ្ដាល ខេត្តកំពង់ស្ពឺ ខេត្តតាកែវ ខេត្តកំពត និងខេត្តកែប) ទៅកាន់បណ្ដាញភាគខាងជើងឆៀងខាងលិច (ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាប) កាត់តាមខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់។

នៅឆ្នាំ ២០១៣ ខ្សែបញ្ជូនតង់ស្យុងខ្ពស់ ២៣០ kV ពីខេត្តកំពត ទៅខេត្តព្រះសីហនុ ស្ថិតក្រោមប្រាក់កម្ចីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) មានប្រវែង ៨៨ km និងខ្សែបញ្ជូនតង់ស្យុងខ្ពស់ ២៣០ kV មួយខ្សែទៀតពីភ្នំពេញ ទៅខេត្តកំពង់ចាម ដែលមានប្រវែង ១១០ km ត្រូវបានដាក់ឲ្យដំណើរការ។ គម្រោងទាំងនេះ បានធ្វើឲ្យបណ្ដាញជាតិគ្របដណ្ដប់លើខេត្តចំនួន ២ បន្ថែមទៀតរួមមាន ខេត្តព្រះសីហនុ និងខេត្តកំពង់ចាម។

### តារាងទី ១១ : បណ្ដាញខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់សំខាន់ៗ

| I | ខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ ១១៥ kV | ចំនួនសៀគ្វី | មុខកាត់ខ្សែ (mm²) | ប្រវែងខ្សែ (km) | ឆ្នាំដំណើរការ | ប្រភពទុន |
|---|---|---|---|---|---|---|
| ១ | អនុស្ថានីយទី ១ - អនុស្ថានីយទី ៣ | ១ | ២x២៥០ | ១១,៥០ | ១៩៩៩ | World Bank |
| ២ | អនុស្ថានីយទី ៣ - អនុស្ថានីយទី ២ | ១ | ២x២៥០ | ១១,៨៥ | ១៩៩៩ | World Bank |
| ៣ | អនុស្ថានីយទី១ - អនុស្ថានីយកំពង់ស្ពឺ | ១ | ១៥០ | ៤០,៩៣ | ២០០២ | BOT |
| ៤ | អនុស្ថានីយកំពង់ស្ពឺ - គិរីរម្យ ១ | ១ | ១៥០ | ៦៥,០៤ | ២០០២ | BOT |

## តារាងទី ១១ : បណ្តាញខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់សំខាន់ៗ(ត)

| I | ខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ ១១៥ kV | ចំនួនសៀគ្វី | មុខកាត់ខ្សែ ($mm^2$) | ប្រវែងខ្សែ (km) | ឆ្នាំដំណើរការ | ប្រភពទុន |
|---|---|---|---|---|---|---|
| ៥ | ព្រំដែនថៃ - អនុស្ថានីយ IE | ២ | ៤០០ | ៤ | ២០០៧ | BOT |
| ៦ | អនុស្ថានីយ IE - អនុស្ថានីយបន្ទាយមានជ័យ | ២ | ៤០០ | ៤៣ | ២០០៧ | BOT |
| ៧ | អនុស្ថានីយបន្ទាយមានជ័យ - អនុស្ថានីយសៀមរាប | ១ | ៤០០ | ៨៥ | ២០០៧ | BOT |
| ៨ | អនុស្ថានីយបន្ទាយមានជ័យ - អនុស្ថានីយបាត់ដំបង | ១ | ៤០០ | ៥៣ | ២០០៧ | BOT |
| ៩ | អនុស្ថានីយទី៤ - អនុស្ថានីយទី១ | ១ | ២x២៥០ | ២៩,៨០ | ២០០៩ | World Bank |
| ១០ | អនុស្ថានីយទី៤ - KEP | ១ | ២x២៥០ | ២២,៨០ | ២០០៩ | World Bank |
| ១១ | KEP - អនុស្ថានីយទី ២ | ១ | ២x២៥០ | ៦,៦០ | ២០០៩ | World Bank |
| ១២ | គិរីរម្យ ១ - គិរីរម្យ ៣ | ១ | ១៥០ | ៣២ | ២០១២ | BOT |
| ១៣ | រោងចក្រវារីអគ្គិសនីស្ទឹងអាតៃ-អនុស្ថានីយអូរសោម | ២ | ៦៣០ | ១៧,៨០ | ២០១៣ | BOT |
| ប្រវែងខ្សែសរុប | | | | ៤២៣,៣២ km | | |

| II | ខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ ២៣០ kV | ចំនួនសៀគ្វី | មុខកាត់ខ្សែ ($mm^2$) | ប្រវែងខ្សែ (km) | ឆ្នាំដំណើរការ | ប្រភពទុន |
|---|---|---|---|---|---|---|
| ១ | ព្រំដែនវៀតណាម - អនុស្ថានីយតាកែវ | ២ | ៤៥០ | ៥០ | ២០០៩ | ADB - NDF |
| ២ | អនុស្ថានីយតាកែវ - អនុស្ថានីយទី៤ | ២ | ៦៣០ | ៤៧ | ២០០៩ | ADB - NDF |
| ៣ | អនុស្ថានីយតាកែវ - អនុស្ថានីយកំពត | ២ | ៤៥០ | ៧៣ | ២០១១ | KfW |
| ៤ | អនុស្ថានីយកំពត - រោងចក្រវារីអគ្គិសនីកំចាយ | ២ | ៦៣០ | ១១ | ២០១១ | BOT |
| ៥ | អនុស្ថានីយទី៤ - អនុស្ថានីយទី៦ - អនុស្ថានីយកំពង់ឆ្នាំង - អនុស្ថានីយពោធិ៍សាត់ - អនុស្ថានីយបាត់ដំបង | ២ | ៦៣០ | ២៩៣,៣៨ | ២០១២ | BOT |
| ៦ | អនុស្ថានីយពោធិ៍សាត់ - អនុស្ថានីយអូរសោម | ២ | ៦៣០ | ១៣២ | ២០១២ | BOT |
| ៧ | អនុស្ថានីយកំពត - អនុស្ថានីយស្ទឹងហាវ | ២ | ៦៣០ | ៨១,៦២ | ២០១៣ | ADB - JICA |
| ៨ | អនុស្ថានីយទី៦(ខាងជើងភ្នំពេញ) - អនុស្ថានីយកំពង់ចាម | ២ | ២x៤០០ | ៩៧,១៨ | ២០១៣ | BOT |
| ៩ | អនុស្ថានីយអូរសោម - រោងចក្រវារីអគ្គិសនីស្ទឹងឫស្សីជ្រុំក្រោម | ២ | ២x៤០០ | ៤២ | ២០១៣ | BOT |
| ប្រវែងខ្សែសរុប | | | | ៨២៧,១៨ km | | |

* NDF : Nordic Development Fund : មូលនិធិអភិវឌ្ឍន៍របស់ Nordic

## តារាងទី ១២ : អនុស្ថានីយអគ្គិសនីតង់ស្យុងខ្ពស់

| ល.រ | អនុស្ថានីយ | តង់ស្យុង (kV) | ចំនួនត្រង់ស្វូម៉ាទ័រ | អានុភាព (MVA) | ឆ្នាំដំណើរការ |
|---|---|---|---|---|---|
| ១ | អនុស្ថានីយទី១ | ១១៥/២២/១៥ | ១ | ៥០ | ១៩៩៩ |
| | | ១១៥/២២ | ១ | ៥០ | |
| ២ | អនុស្ថានីយទី២ | ១១៥/២២/១៥ | ១ | ៥០ | ១៩៩៩ |
| | | ១១៥/២២ | ១ | ៥០ | |

## តារាងទី ១២ : អនុស្ថានីយអគ្គិសនីតង់ស្យុងខ្ពស់ (ត)

| ល.រ | អនុស្ថានីយ | តង់ស្យុង (kV) | ចំនួនត្រង់ស្វូម៉ាទ័រ | អានុភាព (MVA) | ឆ្នាំដំណើរការ |
|---|---|---|---|---|---|
| ៣ | អនុស្ថានីយទី៣ | ១១៥/២២ | ២ | ៥០ | ១៩៩៩ |
| ៤ | អនុស្ថានីយកំពង់ស្ពឺ | ១១៥/២២ | ១ | ៦,៣ | ២០០២ |
| ៥ | អនុស្ថានីយបាត់ដំបង | ១១៥/២២ | ១ | ២៥ | ២០០៧ |
| ៦ | អនុស្ថានីយបន្ទាយមានជ័យ | ១១៥/២២ | ១ | ២៥ | ២០០៧ |
| ៧ | អនុស្ថានីយសៀមរាប | ១១៥/២២ | ១ | ៥០ | ២០០៧ |
| ៨ | អនុស្ថានីយទី៤ (ខាងលិចភ្នំពេញ) | ២៣០/១១៥ | ២ | ២០០ | ២០០៩ |
| | | ១១៥/២២ | ២ | ៥០ | |
| ៩ | អនុស្ថានីយតាកែវ | ២៣០/២២ | ១ | ១៦ | ២០០៩ |
| ១០ | អនុស្ថានីយកំពត | ២៣០/២២ | ១ | ៥០ | ២០១១ |
| ១១ | អនុស្ថានីយកំពង់ឆ្នាំង | ២៣០/២២ | ១ | ២៥ | ២០១២ |
| ១២ | អនុស្ថានីយពោធិ៍សាត់ | ២៣០/២២ | ១ | ២៥ | ២០១២ |
| ១៣ | អនុស្ថានីយបាត់ដំបង | ២៣០/១១៥/២២ | ១ | ៩០ | ២០១២ |
| ១៤ | អនុស្ថានីយទី៥ (SWS) | ១១៥/២២ | ២ | ៥០ | ២០១៣ |
| ១៥ | អនុស្ថានីយស្ទឹងហាវ | ២៣០/២២ | ១ | ៥០ | ២០១៣ |
| ១៦ | បន្ថែមអានុភាពនៃតង់ស្យុង ១១៥ kV ក្នុងអនុស្ថានីយទី១, អនុស្ថានីយទី២ និងអនុស្ថានីយទី៣ | ១១៥/២២ | ១ | ៥០ | ២០១៣ |
| | | ១១៥/២២ | ២ | ៧៥ | |
| ១៧ | អនុស្ថានីយទី៦ (ខាងជើងភ្នំពេញ) | ១១៥/២២ | ២ | ៥០ | ២០១៣ |
| | | ២៣០/១១៥ | ២ | ២០០ | |
| ១៨ | អនុស្ថានីយអូរសោម | ២៣០/១១៥/២២ | ១ | ១៥០ | ២០១៣ |
| ១៩ | អនុស្ថានីយកំពង់ចាម | ១១៥/២២ | ១ | ៥០ | ២០១៣ |

បណ្តាញចែកចាយ និងបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ជាទូទៅ គឺមានតង់ស្យុង ២២ kV និងតង់ស្យុងទាប ០,៤/០,២២ kV ។ អំឡុងឆ្នាំ២០០៩ និង ២០១០ បណ្តាញចែកចាយនៅរាជធានីភ្នំពេញ ខេត្តកំពង់ស្ពឺ ខេត្តព្រៃវែង ស្រុកបានលុង (ខេត្តរតនគិរី) ខេត្តស្ទឹងត្រែង និងខេត្តព្រះសីហនុ ត្រូវបានសាងសង់បន្ថែម ដើម្បីបង្កើនប្រសិទ្ធភាពនៃការផ្គត់ផ្គង់។ ចំពោះទិន្នន័យលម្អិតរបស់ខ្សែបណ្តាញប្រភេទតង់ស្យុងខុសៗគ្នាដូចមានបង្ហាញក្នុងតារាងបន្ទាប់។

គម្រោងអគ្គិសនីភាវូបនីយកម្មជនបទ ស្ថិតក្រោមប្រាក់កម្ចីរបស់ធនាគារចិន (China Exim Bank) បានចាប់ផ្តើមសាងសង់ប្រព័ន្ធចែកចាយតង់ស្យុងមធ្យម និងត្រង់ស្វូម៉ាទ័រនៅដើមឆ្នាំ ២០១២ និងរំពឹងថានឹងសាងសង់ជាស្ថាពរនៅឆ្នាំ ២០១៤ ដែលគ្របដណ្តប់ខេត្តចំនួន ៤ ដូចជា ខេត្តកំពង់ចាម ខេត្តព្រៃវែង ខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ ដែលមានប្រវែងសរុប ២.០០០ km ។ បន្ថែមពីនេះ គម្រោងអគ្គិសនីភាវូបនីយកម្មជនបទ ស្ថិតក្រោមប្រាក់មូលនិធិអាល្លឺម៉ង់ (KfW) និងមូលនិធិរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលគ្របដណ្តប់ខេត្តចំនួន ៩ ដូចជា ខេត្តតាកែវ ខេត្តកំពត ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ក្រុងប៉ៃលិន ខេត្តឧត្តរមានជ័យ ខេត្តព្រះវិហារ និងខេត្តស្វាយរៀង ស្ថិតក្រោមការរៀបចំដេញថ្លៃ ដែលមានប្រវែងសរុបប្រមាណ ៤.៥០០ km ។

## តារាងទី ១៣ : ទិន្នន័យសង្ខេបនៃប្រព័ន្ធចែកចាយ និងបញ្ជូនរង

| ទីតាំង | ប្រភេទ | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|---|---|
| ភ្នំពេញ និង កណ្តាល | ប្រវែងខ្សែ,cct-km | ១.៥១៨,៥៤ | ១.៦០២,៨៥ | ១.៨៧៧,១៦ | ២.០៥៨,១៦ | ២.៥៧២,៥៣ | ៣.៥៨៥,៧៦ |
| | តង់ស្យុងមធ្យម | ៦៩៨,៧១ | ៧៤១,៨១ | ៩៣២,៦៤ | ១.០៧៦,០៨ | ១.២៨៧,២៦ | ២.២០៣,៥៥ |
| | តង់ស្យុងទាប | ៨១៩,៨៣ | ៨៦១,០៤ | ៩៤៤,៥២ | ៩៨២,០៨ | ១.២៨៥,២៧ | ១.៣៨២,២១ |
| | ចំនួនបន្ទប់ភ្លើង | ១.១៩៦ | ១.៤១២ | ១.៥៩១ | ១.៨៧៥ | ២.១៧០ | ២.៣៨៥ |
| កំពង់ស្ពឺ | ប្រវែងខ្សែ,cct-km | ៧៥,០៣ | ១១៦,២២ | ១១៥,៨៤ | ១២៨,១៥ | ១៥១,៦៧ | ៨០៥,៥៨ |
| | តង់ស្យុងមធ្យម | ២០,១៣ | ៦១,៣២ | ៦០,៩៤ | ៧៤,០៧ | ៩៥,៨៨ | ៦៧៣,២០ |
| | តង់ស្យុងទាប | ៥៤,៩០ | ៥៤,៩០ | ៥៤,៩០ | ៥៤,០៨ | ៥៥,៧៩ | ១៣២,៣៨ |
| | ចំនួនបន្ទប់ភ្លើង | ២២ | ២៣ | ២៣ | ៦២ | ៧១ | ៨៧ |
| សៀមរាប | ប្រវែងខ្សែ,cct-km | ២៧៧,០៣ | ២៨៧,១៩ | ៤១៧,០២ | ៦២៦,១០ | ៦៥៧,៥៦ | ៧៣៦,៤១ |
| | តង់ស្យុងមធ្យម | ១៥៤,៩១ | ១៦០,៤៨ | ១៩២,០៦ | ៣៥០,៣២ | ៣៦៧,៧៣ | ៤១៤,៤៤ |
| | តង់ស្យុងទាប | ១២២,១២ | ១២៦,៧១ | ២២៤,៩៦ | ២៧៥,៧៨ | ២៨៩,៨៣ | ៣២១,៩៧ |
| | ចំនួនបន្ទប់ភ្លើង | ៩១ | ៩៥ | ១២៦ | ១៥៨ | ១៨៤ | ១៩៦ |
| ព្រះសីហនុ | ប្រវែងខ្សែ,cct-km | ១៣៩,៥៥ | ១៧៣,៧៨ | ២៨៣,៨៣ | ២៩៧,៧០ | ២៩៧,៧០ | ៣០៤,៣៧ |
| | តង់ស្យុងមធ្យម | ៦៥,០៩ | ៩៩,៣២ | ២០៣,៣៦ | ២០៣,៩៦ | ២០៣,៩៦ | ២០៧,៩៦ |
| | តង់ស្យុងទាប | ៧៤,៤៦ | ៧៤,៤៦ | ៨០,៤៧ | ៩៣,៧៤ | ៩៣,៧៤ | ៩៦,៤១ |
| | ចំនួនបន្ទប់ភ្លើង | ៦៤ | ៦៩ | ១៤៤ | ១៥៥ | ១៧៨ | ១៨៧ |
| កំពង់ចាម | ប្រវែងខ្សែ,cct-km | ៥០,០៨ | ៥២,៦០ | ១៤១,៦២ | ១៤៤,០១ | ១៤៥,៤៥ | ១៤៩,៦៩ |
| | តង់ស្យុងមធ្យម | ២២,៥៦ | ២២,៨៤ | ៥០,៨០ | ៥០,៩៧ | ៥១,២៨ | ៥១,៦០ |
| | តង់ស្យុងទាប | ២៧,៥២ | ២៩,៧៦ | ៩០,៨២ | ៩៣,០៤ | ៩៤,១៧ | ៩៨,០៩ |
| | ចំនួនបន្ទប់ភ្លើង | ២៩ | ៣១ | ៥២ | ៥៩ | ៥៩ | ៦៤ |
| ពញាក្រែក | ប្រវែងខ្សែ,cct-km | ៣៣,៣៥ | ៣៣,៣៥ | ៣៩,៥៥ | ៤៣,៨៥ | ៤៥,០២ | ៤៥,១៧ |
| | តង់ស្យុងមធ្យម | ២២,៥៥ | ២២,៥៥ | ២៣,៥៩ | ២៦,៩០ | ២៧,១២ | ២៧,១២ |
| | តង់ស្យុងទាប | ១០,៨០ | ១០,៨០ | ១៥,៩៦ | ១៦,៩៥ | ១៧,៩០ | ១៨,០៥ |
| | ចំនួនបន្ទប់ភ្លើង | ២៩ | ២៩ | ២៧ | ៣១ | ៣១ | ២១ |
| មេមត់ | ប្រវែងខ្សែ,cct-km | ៤២,៤១ | ៤៥,១៧ | ៤៦,៣៧ | ៤៦,៤៦ | ៤៦,៤៦ | ៤៨,២៤ |
| | តង់ស្យុងមធ្យម | ២១,៦៤ | ២៣,១០ | ២៣,១០ | ២៣,១៧ | ២៣,១៧ | ២៣,១៧ |
| | តង់ស្យុងទាប | ២០,៧៧ | ២២,០៧ | ២៣,២៧ | ២៣,២៩ | ២៣,២៩ | ២៥,០៧ |
| | ចំនួនបន្ទប់ភ្លើង | ២៧ | ៣០ | ៣១ | ៣៧ | ៣៧ | ២៤ |
| តាកែវ | ប្រវែងខ្សែ,cct-km | ១០៥,៣៩ | ១០៤,១៧ | ១០៥,៩៣ | ២៨០,១៤ | ២៨០,១៤ | ៣៦៧,៩៦ |
| | តង់ស្យុងមធ្យម | ៣១,៣០ | ៣១,២៩ | ៣១,៧៧ | ១៥៨,៣១ | ១៥៨,៣១ | ១៥៨,៣១ |
| | តង់ស្យុងទាប | ៧៤,១០ | ៧២,៨៨ | ៧៤,១៦ | ១២១,៨៣ | ១២១,៨៣ | ២០៩,៦៥ |
| | ចំនួនបន្ទប់ភ្លើង | ២៩ | ៣១ | ៣១ | ១០១ | ១០៤ | ១១៣ |
| បាត់ដំបង | ប្រវែងខ្សែ,cct-km | ១៧២,១១ | ២១៦,២១ | ២៤៨,៧៣ | ៦៤២,៨៩ | ៦៤២,៩១ | ៦៩១,៥៣ |
| | តង់ស្យុងមធ្យម | ៥៦,១៨ | ៤៤,០៥ | ៧៤,៨៩ | ៤០១,០៣ | ៤០១,០៣ | ៤៤៤,១៩ |
| | តង់ស្យុងទាប | ១១៥,៩៣ | ១៧២,១៦ | ១៧៣,៨៤ | ២៤១,៨៦ | ២៤១,៨៨ | ២៤៧,៣៤ |
| | ចំនួនបន្ទប់ភ្លើង | ៥៥ | ៩៦ | ៧៩ | ២២៧ | ២២៨ | ២៤០ |

## តារាងទី ១៣ : ទិន្នន័យសង្ខេបនៃប្រព័ន្ធចែកចាយ និងបញ្ជូនរង(ត)

| ទីតាំង | ប្រភេទ | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|---|---|
| កំពត | ប្រវែងខ្សែ,cct-km | ៩២,២៩ | ៩៤,៧៨ | ១៤៧,៦៧ | ២៨៩,៨៦ | ៣៣៨,៨៩ | ៣៣៨,៨៩ |
| | តង់ស្យុងមធ្យម | ៣២,៧៧ | ៣២,៧៧ | ៦៨,៤២ | ២០៥,៦១ | ២២៦,៦៤ | ២២៦,៦៤ |
| | តង់ស្យុងទាប | ៥៩,៥១ | ៦២,០១ | ៧៩,២៥ | ៨៤,២៥ | ១១២,២៥ | ១១២,២៥ |
| | ចំនួនបន្ទប់ភ្លើង | ២៨ | ៣០ | ៣៨ | ៧១ | ៩០ | ១០៥ |
| កំពង់ត្រាច | ប្រវែងខ្សែ,cct-km | ៣៩,៧៣ | ៣៩,៩៣ | ៤៥,១៨ | ៤៥,៤២ | ៦០,០២ | ៧៥,៦៥ |
| | តង់ស្យុងមធ្យម | ២១,៦៨ | ២១,៦៨ | ២៥,០៥ | ២៥,០៥ | ៣៩,៤៥ | ៤៦,៧៨ |
| | តង់ស្យុងទាប | ១៨,០៥ | ១៨,២៥ | ២០,១៣ | ២០,៣៧ | ២០,៥៧ | ២៨,៨៧ |
| | ចំនួនបន្ទប់ភ្លើង | ១៣ | ១២ | ២៤ | ៣១ | ៣៦ | ៤៤ |
| ព្រៃវែង | ប្រវែងខ្សែ,cct-km | ៤៥,៧២ | ៨៣,១៩ | ១០០,២៧ | ១០០,២៧ | ១១២,៤៤ | ៤៧៣,៩៦ |
| | តង់ស្យុងមធ្យម | ១០,៣២ | ៤៧,៧៩ | ៥៣,១២ | ៥៣,១២ | ៥៥,៦២ | ៤១៧,១៤ |
| | តង់ស្យុងទាប | ៣៥,៤០ | ៣៥,៤០ | ៤៧,១៥ | ៤៧,១៥ | ៥៦,៨២ | ៥៦,៨២ |
| | ចំនួនបន្ទប់ភ្លើង | ១៤ | ១៤ | ១៧ | ១៧ | ២០ | ២១ |
| បន្ទាយមានជ័យ | ប្រវែងខ្សែ,cct-km | ១៤៦,៦៨ | ១៤៦,៦៩ | ១៣៦,៤០ | ១៥៩,៧១ | ១៧១,៣២ | ១៧៣,៩១ |
| | តង់ស្យុងមធ្យម | ៣៣,៦៦ | ៣៣,៦៦ | ២៩,៥០ | ៤១,៤២ | ៤៦,២៦ | ៤៨,៨៥ |
| | តង់ស្យុងទាប | ១១៣,០៣ | ១១៣,០៣ | ១០៦,៩០ | ១១៨,២៩ | ១២៥,០៦ | ១២៥,០៦ |
| | ចំនួនបន្ទប់ភ្លើង | ៣២ | ៣២ | ៣៣ | ៣៩ | ៥០ | ៥៥ |
| មង្គលបូរី | ប្រវែងខ្សែ,cct-km | ៤៦,១០ | ៤៦,៩៥ | ៤៩,៦០ | ៦៣,៨៩ | ៨២,២២ | ៨២,២២ |
| | តង់ស្យុងមធ្យម | ១៣,៤០ | ១៤,២៥ | ១៥,៣៧ | ២៩,៦៦ | ៤៥,៤៨ | ៤៥,៤៨ |
| | តង់ស្យុងទាប | ៣២,៧០ | ៣២,៧០ | ៣៤,២៣ | ៣៤,២៣ | ៣៦,៧៤ | ៣៦,៧៤ |
| | ចំនួនបន្ទប់ភ្លើង | ១៣ | ១៣ | ១៧ | ២៦ | ៣៥ | ៣៥ |
| ស្ទឹងត្រែង | ប្រវែងខ្សែ,cct-km | ៤៧,២៣ | ១១១,៤៣ | ៧៤,០៦ | ១៣២,៩៣ | ១៣២,៩៣ | ២០២,៤៣ |
| | តង់ស្យុងមធ្យម | ១២,៩៨ | ៧៧,១៨ | ៣៩,៨១ | ៩២,១៨ | ៩២,១៨ | ១៣២,០៨ |
| | តង់ស្យុងទាប | ៣៤,២៥ | ៣៤,២៥ | ៣៤,២៥ | ៤០,៧៥ | ៤០,៧៥ | ៧០,៣៥ |
| | ចំនួនបន្ទប់ភ្លើង | ១២ | ១២ | ១៤ | ២៥ | ២៣ | ៣៧ |
| រតនគិរី | ប្រវែងខ្សែ,cct-km | ៥៣,០៣ | ៥៦,០២ | ៥៤,១២ | ១២៤,៤២ | ១៣០,៣០ | ១៣៨,៧០ |
| | តង់ស្យុងមធ្យម | ២១,៦៩ | ២៤,២៨ | ២០,២៩ | ៩០,១៨ | ៩០,២៥ | ៩១,៧៤ |
| | តង់ស្យុងទាប | ៣១,៣៤ | ៣១,៧៤ | ៣៣,៨៣ | ៣៤,២៤ | ៤០,០៥ | ៤៦,៩៦ |
| | ចំនួនបន្ទប់ភ្លើង | ១៩ | ១៣ | ១៤ | ៣០ | ៥០ | ៧២ |
| ស្វាយរៀង | ប្រវែងខ្សែ,cct-km | ២០៩,២៧ | ២១២,៣៧ | ២១៨,៣៦ | ៤០៦,១៧ | ៤១៧,៥១ | ៤១៩,០៩ |
| | តង់ស្យុងមធ្យម | ១២០,២៩ | ១២១,៩៩ | ១២៧,៩៨ | ៣១៤ | ៣២៥,៣៤ | ៣២៥,៣៤ |
| | តង់ស្យុងទាប | ៨៨,៩៨ | ៩០,៣៨ | ៩០,៣៨ | ៩២,១៧ | ៩២,១៧ | ៩៣,៧៥ |
| | ចំនួនបន្ទប់ភ្លើង | ៤០ | ៤០ | ៥៣ | ៥៦ | ៧១ | ៥៤ |
| បាវិត | ប្រវែងខ្សែ,cct-km | ៣០,៣៥ | ៣០,៣៥ | ៣១,៧៤ | ៣៩,៦៨ | ១៧៣,៩៩ | ១៨៥,៥៦ |
| | តង់ស្យុងមធ្យម | ១១,២១ | ១១,២១ | ១១,២១ | ១១,៩៥ | ១៤១,១៩ | ១៤១,២៤ |
| | តង់ស្យុងទាប | ១៩,១៤ | ១៩,១៤ | ២០,៥៣ | ២៧,៧៣ | ៣២,៨០ | ៤៤,៣២ |
| | ចំនួនបន្ទប់ភ្លើង | ៣១ | ៣២ | ៣៥ | ៥០ | ៥០ | ២១ |

## តារាងទី ១៣ : ទិន្នន័យសង្ខេបនៃប្រព័ន្ធចែកចាយ និងបញ្ជូនរង( ត )

| ទីតាំង | ប្រភេទ | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|---|---|
| មណ្ឌលគិរី | ប្រវែងខ្សែ,cct-km | - | - | ៦១,៦៧ | ៦៤,៨៨ | ១០៩,៣៩ | ១២០,៣៩ |
| | តង់ស្យុងមធ្យម | - | - | ២៩,៦៧ | ៣២,២៤ | ៦៨,៩៣ | ៧២,៩៣ |
| | តង់ស្យុងទាប | - | - | ៣២ | ៣២,២៤ | ៤០,៤៦ | ៤៧,៤៦ |
| | ចំនួនបន្ទប់ភ្លើង | - | - | ៤០ | ៤២ | ៤៩ | ៥៤ |
| កែវសីមា | ប្រវែងខ្សែ,cct-km | - | - | ៤៤ | ៤៤ | ៦៣,៦៥ | ៧៧,៩១ |
| | តង់ស្យុងមធ្យម | - | - | ២០ | ២០ | ៣២,៥០ | ៤៥,៨០ |
| | តង់ស្យុងទាប | - | - | ២៤ | ២៤ | ៣១,១៥ | ៣២,១១ |
| | ចំនួនបន្ទប់ភ្លើង | - | - | ១៦ | ១៦ | ២២ | ២២ |
| ក្រចេះ | ប្រវែងខ្សែ,cct-km | - | - | - | ៤៦,៧៩ | ១៣៥,៥៤ | ១៦០,១៤ |
| | តង់ស្យុងមធ្យម | - | - | - | ២៨,៧៥ | ១១៦,៨៤ | ១២២,៥៩ |
| | តង់ស្យុងទាប | - | - | - | ១៨,០៤ | ១៨,៧០ | ៣៧,៥៥ |
| | ចំនួនបន្ទប់ភ្លើង | - | - | - | ១៣ | ៤៤ | ៤៩ |
| ស្នួល | ប្រវែងខ្សែ,cct-km | - | - | - | - | ៣២,៥៨ | ៣២,៦៩ |
| | តង់ស្យុងមធ្យម | - | - | - | - | ១៩,០៧ | ១៩,០៧ |
| | តង់ស្យុងទាប | - | - | - | - | ១៣,៥១ | ១៣,៦១ |
| | ចំនួនបន្ទប់ភ្លើង | - | - | - | - | ២៥ | ២៨ |
| សរុប | ប្រវែងខ្សែ,cct-km | ៣.១២៣,៨៩ | ៣.៤៥៣,២៥ | ៤.២៣៩,១២ | ៥.៧៨៥,០៨ | ៦.៨០០,២២ | ៩.២១៦,២៥ |
| | តង់ស្យុងមធ្យម | ១.៣៧១,០៧ | ១.៥៩១,៥៧ | ២.០៣៣,៥៧ | ៣.៣០៨,៩៧ | ៣.៩១៥,៤៩ | ៥.៩៣៩,២២ |
| | តង់ស្យុងទាប | ១.៧៥២,៨៣ | ១.៨៦១,៦៨ | ២.២០៥,៥៥ | ២.៤៧៦,១១ | ២.៨៨៨,៧៣ | ៣.២៧៧,០២ |
| | ចំនួនបន្ទប់ភ្លើង | ១.៧៤៤ | ២.០១៤ | ២.៤០៥ | ៣.១២១ | ៣.៦២៧ | ៣.៩១៤ |

## មូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ នៃអគ្គិសនីកម្ពុជា

រាជរដ្ឋាភិបាលបានចេញព្រះរាជក្រឹត្យលេខ នស/រកត/១២០៤/០៤៨ ចុះថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០០៤ ស្តីពីការបង្កើតស្ថាប័ន មូលនិធិអគ្គិសនីភាវូបនីយកម្មជនបទនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីជំរុញការអភិវឌ្ឍន៍អគ្គិសនីភាវូបនីយកម្មជនបទ។ បន្ទាប់មកនៅថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១២ រាជរដ្ឋាភិបាលកម្ពុជា បានចេញព្រះរាជក្រឹត្យថ្មីមួយទៀតលេខ នស/រកត/០៨១២/៧៣៥ ដោយធ្វើវិសោធនកម្មមាត្រាខ្លះនៃព្រះរាជក្រឹត្យចាស់ ដោយផ្ទេរស្ថាប័នមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជាវិញ ដើម្បីឲ្យកម្ពុជាខ្លួនឯងអាចម្ចាស់ការបន្តប្រតិបត្តិការការងាររបស់មូលនិធិអគ្គិសនីភាវូបនីយកម្មជនបទផង និងក៏នៅតែអាចទទួលនូវអំណោយ និងជំនួយនានាពីខាងក្រៅមកជួយអភិវឌ្ឍន៍អគ្គិសនីភាវូបនីយកម្មជនបទកម្ពុជាបានផង។

## សកម្មភាពការងារដែល ម.អ.ជ សម្រេចបានចាប់តាំងពីថ្ងៃបង្កើត ម.អ.ជ ឆ្នាំ ២០០៤ រហូតមកដល់ចុងឆ្នាំ ២០១៣

ក្នុងឆ្នាំ២០១៣ អគ្គិសនីកម្ពុជាបានផ្តល់ថវិកាចំនួន ៤ លានដុល្លារអាមេរិក សម្រាប់ចំណាយប្រតិបត្តិការរបស់ ម.អ.ជ. និងសម្រាប់អនុវត្តន៍កម្មវិធីអភិវឌ្ឍន៍អគ្គិសនីភាវូបនីយកម្មជនបទចំនួន៣ រួមមាន៖

១. **កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ៖** គោលបំណងនៃកម្មវិធីនេះ គឺជួយដល់គ្រួសារក្រីក្ររស់នៅតំបន់ជនបទ ដើម្បីឲ្យពួកគាត់អាចទទួលបានការតភ្ជាប់ចរន្តអគ្គិសនីពីប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ដោយការផ្តល់ប្រាក់កម្ចីអនុគ្រោះគ្មានការប្រាក់ឲ្យពួកគាត់ខ្ចីយកទៅ៖ ១-បង់ថ្លៃភ្ជាប់ចរន្តឲ្យអ្នកផ្គត់ផ្គង់ ២-បង់ថ្លៃប្រាក់កក់ឲ្យអ្នកផ្គត់ផ្គង់ ៣-ចំណាយលើការទិញ និងរាយខ្សែពីចំណុចភ្ជាប់ចរន្តមកដល់ផ្ទះរបស់ខ្លួន និង ៤-ចំណាយលើការរៀបចំខ្សែបណ្តាញ និងឧបករណ៍អគ្គិសនីក្នុងផ្ទះ ដើម្បីតភ្ជាប់ចរន្តអគ្គិសនីចូលផ្ទះ។ ប្រាក់កម្ចីនេះនឹងទូទាត់តាមរយៈអ្នកផ្គត់ផ្គង់អគ្គិសនី ដែលជាអ្នកទទួលខុសត្រូវក្នុងការបង់សងត្រឡប់មក ម.អ.ជ. វិញ ដោយបានមកពីការប្រមូលពីអ្នកខ្ចីដែលត្រូវបង់សងរំលស់១ខែម្តងមក ម.អ.ជ. ក្នុងរយៈពេល ៣ឆ្នាំ។ ចំនួនទឹកប្រាក់កម្ចីនេះ គឺមិនលើសពី ៤៨០.០០០ រៀល ក្នុង ១ គ្រួសារ។ រហូតមកដល់ពេលនេះ មានគ្រួសារជនបទចំនួន ៦.៣៣១ គ្រួសារ ស្មើនឹង ៣០.៥០៧ នាក់ ដែលបានទទួលផលដោយផ្ទាល់ក្រោមកម្មវិធីនេះ។

២. **កម្មវិធីប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ៖** គោលបំណងនៃកម្មវិធីនេះ គឺជួយសម្រួលឲ្យគ្រួសារជនបទរស់នៅតំបន់ដាច់ស្រយាល ដែលខ្សែបណ្តាញអគ្គិសនីមិនទាន់អាចពង្រីកទៅដល់ក្នុងរយៈពេលយូរ អាចទទួលបានអគ្គិសនីប្រើប្រាស់តាមរយៈប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ។ ម.អ.ជ. ជួយផ្តល់ប្រាក់ឧបត្ថម្ភធនចំនួន ១០០ ដុល្លារអាមេរិក ក្នុង ១ ប្រព័ន្ធ ដល់គ្រួសារជនបទ ដើម្បីជួយកាត់បន្ថយការទូទាត់ថ្លៃទិញប្រព័ន្ធ ហើយអ្នកទិញត្រូវបង់ថ្លៃសល់ពីការឧបត្ថម្ភធននេះ រំលស់ប្រចាំខែដោយគ្មានការប្រាក់មក ម.អ.ជ. វិញ ក្នុងរយៈពេល ៤ឆ្នាំ។ ក្រោយពេលបង់រំលស់អស់ជាស្ថាពរ ប្រព័ន្ធនេះនឹងក្លាយជាកម្មសិទ្ធិរបស់អ្នកទិញ។ រហូតដល់ពេលនេះ មានគ្រួសារជនបទចំនួន ១៦.០០០ គ្រួសារ ស្មើនឹង ៧៣.៦០០ នាក់ បានទទួលផលដោយផ្ទាល់ក្រោមកម្មវិធីនេះ។

៣. **កម្មវិធីជួយទុនសម្រាប់ពង្រីកការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ៖** គោលបំណងនៃកម្មវិធីនេះគឺជួយសម្រួលឲ្យអ្នកផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ ដែលមានអាជ្ញាប័ណ្ណស្របច្បាប់ អាចមានទុនសម្រាប់វិនិយោគពង្រីកការផ្គត់ផ្គង់អគ្គិសនី ឲ្យពេញដែនអាជ្ញាប័ណ្ណចែកចាយរបស់ខ្លួន ដើម្បីឲ្យប្រជាពលរដ្ឋគ្រប់គ្រួសារអាចភ្ជាប់ចរន្តប្រើប្រាស់តាមលទ្ធភាពរបស់ខ្លួន ។ រហូតដល់ពេលនេះ មានអ្នកកាន់អាជ្ញាប័ណ្ណចំនួន ២៤ បានទទួលផលដោយផ្ទាល់ក្រោមកម្មវិធីនេះ។

## ផែនការអភិវឌ្ឍន៍វិស័យថាមពលអគ្គិសនីនៅព្រះរាជាណាចក្រកម្ពុជា

### គោលនយោបាយអភិវឌ្ឍន៍វិស័យថាមពល

រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវគោលនយោបាយអភិវឌ្ឍន៍វិស័យថាមពលអគ្គិសនីនៅ ខែ តុលា ឆ្នាំ ១៩៩៤ ដែលមានទិសដៅដូចខាងក្រោម៖

- ផ្តល់នូវការផ្គត់ផ្គង់ថាមពលអគ្គិសនីឲ្យបានគ្រប់គ្រាន់ទូទាំងប្រទេសកម្ពុជា ក្នុងតម្លៃសមរម្យ
- ធានានូវការផ្គត់ផ្គង់ថាមពលអគ្គិសនីឲ្យមាននិរន្តភាព និងសុវត្ថិភាព ដែលធ្វើឲ្យមានភាពងាយស្រួលដល់ការវិនិយោគក្នុងប្រទេសកម្ពុជា និងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។
- ជួយជំរុញនូវរបកគំហើញថ្មីៗ និងការអភិវឌ្ឍន៍នៃប្រភពផលិតថាមពលដែលមិនប៉ះពាល់ដល់បរិស្ថាន និងសង្គម ដែលជាតម្រូវការចាំបាច់សម្រាប់ផ្គត់ផ្គង់ថាមពលដល់គ្រប់វិស័យទាំងអស់នៃសេដ្ឋកិច្ចជាតិ។
- លើកទឹកចិត្តនូវការប្រើប្រាស់ថាមពលអគ្គិសនីឲ្យមានប្រសិទ្ធភាព និងកាត់បន្ថយផលប៉ះពាល់បរិស្ថាននូវកម្រិតអប្បបរមាពីប្រភពផ្គត់ផ្គង់ និងការប្រើប្រាស់ ។

## ការព្យាករណ៍តម្រូវការថាមពល

ដោយផ្អែកទៅលើឯកសារស្តីពីផែនការមេ នៃការអភិវឌ្ឍន៍វិស័យថាមពលអគ្គិសនី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានរៀបចំឡើងនៅឆ្នាំ ២០០៧ បានកត់សម្គាល់ថា តម្រូវការថាមពលអគ្គិសនី នឹងមានកំណើនដ៏គួរឲ្យកត់សម្គាល់មួយក្នុងរយៈពេល ១៤ ឆ្នាំខាងមុខនេះ។ តម្រូវការសម្រាប់ផលិតថាមពលនៅព្រះរាជាណាចក្រកម្ពុជា នឹងមានកំណើនពី ១.១០៦,៨៨ GWh និង ២៧៨,៩២ MW នៅឆ្នាំ ២០០៦ ទៅ ៩.២០៥ GWh និង ១.៦៩៩ MW នៅឆ្នាំ ២០២០។ ដើម្បីបំពេញតម្រូវការនាពេលអនាគត រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតផែនការអភិវឌ្ឍន៍ថាមពលរហូតដល់ឆ្នាំ ២០២៤ ។

មួយភាគធំនៃកំណើនតម្រូវការប្រើប្រាស់ថាមពលស្ថិតនៅភាគខាងត្បូងនៃប្រទេស ដែលរួមបញ្ចូលទាំងរាជធានីភ្នំពេញផងដែរ ។ តារាងខាងក្រោមពណ៌នាពីការព្យាករណ៍អានុភាពអតិបរមា និងថាមពលបញ្ចូញសម្រាប់ព្រះរាជាណាចក្រកម្ពុជា។

**តារាងទី ១៤ : ការព្យាករណ៍តម្រូវការថាមពលអគ្គិសនី នៅព្រះរាជាណាចក្រកម្ពុជា**

| ករណីមូលដ្ឋាន | ២០១៣ | ២០១៥ | ២០២០ |
|---|---|---|---|
| អានុភាពអតិបរមាក្នុងបណ្តាញជាតិ (MW) | ៦៩១,៧២* | ៨១៤ | ១.៩៥២ |
| អានុភាពអតិបរមាក្នុងប្រទេស (MW) | ៨៥៦ | ១.០៧៨ | ១.៦៩៩ |
| ថាមពលក្នុងបណ្តាញជាតិ (GWh) | ៣.៦៨៨,៩៩* | ៤.៩៩៩ | ៨.០១៩ |
| ថាមពលក្នុងប្រទេស (GWh) | ៤.៩៥៣ | ៥.៧១៧ | ៩.២០៥ |

* ថាមពល និងអានុភាពអតិបរមាក្នុងបណ្តាញជាតិ គឺជាទិន្នន័យជាក់ស្តែងក្នុងឆ្នាំ ២០១៣

## ផែនការមេនៃការផលិតថាមពល

ផែនការមេនៃការផលិតថាមពល ត្រូវបានអភិវឌ្ឍន៍ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដូចខាងក្រោម ៖

- ការផលិតថាមពលដើរដោយរោងចក្រអគ្គិសនីដែលមានស្រាប់ សម្រាប់ប្រព័ន្ធភ្នំពេញនៅពេលបន្ទុកអតិបរមា។
- ប្រើប្រាស់ម៉ាស៊ីនឌីយ៉ែស្សែលធុនតូច និងមធ្យម ដើម្បីជួយក្នុងការផលិតថាមពល សម្រាប់ចែករំលែកក្នុងបន្ទុកធម្មតា និងមានបន្ទុកអតិបរមានៅតាមបណ្តាខេត្ត-ក្រុង (សម្រាប់រយៈពេលខ្លី)។
- ពង្រីកការអភិវឌ្ឍន៍ផ្នែកវារីអគ្គិសនី ដោយមូលដ្ឋាននៃការអភិវឌ្ឍន៍លើរោងចក្រវារីអគ្គិសនីធុនតូច ដែលមានភាពងាយស្រួលក្នុងការចូលអភិវឌ្ឍដូចជា: រោងចក្រវារីអគ្គិសនីគិរីរម្យ, និងគម្រោងរោងចក្រវារីអគ្គិសនីធុនមធ្យម និងធំ ជាបន្តបន្ទាប់ដូចជា: រោងចក្រវារីអគ្គិសនីកំចាយ រោងចក្រវារីអគ្គិសនីស្ទឹងអាតៃ, រោងចក្រវារីអគ្គិសនីស្ទឹងឫស្សីជ្រុំក្រោម, រោងចក្រវារីអគ្គិសនីបាត់ដំបង, រោងចក្រវារីអគ្គិសនីស្រែពកក្រោម២ ឬ រោងចក្រវារីអគ្គិសនីសេសានក្រោម។

## ផែនការអភិវឌ្ឍន៍ផ្នែកផលិតកម្មសម្រាប់ឆ្នាំ ២០១៤ - ២០២០

| ល.រ | ឈ្មោះគម្រោង | ប្រភេទ | អានុភាព (MW) | ឆ្នាំ ដំណើរការ |
|---|---|---|---|---|
| ១ | រោងចក្រវារីអគ្គិសនីស្ទឹងតាតៃ | វារីអគ្គិសនី | ២៤៦ | ២០១៤ |
| ២ | រោងចក្រវារីអគ្គិសនីស្ទឹងឫស្សីជ្រុំក្រោម | វារីអគ្គិសនី | ៣៣៨ | ២០១៤ |
| ៣ | រោងចក្រអគ្គិសនីធ្យូងថ្ម (CIIDG) នៅខេត្តព្រះសីហនុ ដំហានទី១: ៧០០ MW | ធ្យូងថ្ម | ២៤០ | ២០១៥ |
| ៤ | រោងចក្រវារីអគ្គិសនីសេសានក្រោម២ | វារីអគ្គិសនី | ៤០០ | ២០១៦ |
| ៥ | រោងចក្រអគ្គិសនីធ្យូងថ្ម (CIIDG) នៅខេត្តព្រះសីហនុ ១៣៥ MW | ធ្យូងថ្ម | ១២០ | ២០១៧ |
| ៦ | រោងចក្រវារីអគ្គិសនីស្ទឹងជាយអារ៉ែង | វារីអគ្គិសនី | ១០៨ | ២០២០ |
| សរុប | | | ១.៤៥២ MW | |

## ផែនការមេនៃប្រព័ន្ធខ្សែបញ្ជូន

## ផែនការអភិវឌ្ឍន៍ផ្នែកប្រព័ន្ធខ្សែបញ្ជូន សម្រាប់ឆ្នាំ ២០១៤ - ២០២០

| ល.រ | ខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ ១១៥ kV | ចំនួន សៀគ្វី | ប្រវែងខ្សែ (km) | ឆ្នាំ ដំណើរការ | ដៃគូអភិវឌ្ឍន៍ |
|---|---|---|---|---|---|
| ១ | អនុស្ថានីយស្ទឹងហាវ - អនុស្ថានីយខេត្តព្រះសីហនុ | ២ | ១១ | ២០១៤ | JICA |
| ២ | អនុស្ថានីយឈូក - អនុស្ថានីយបន្ទាយមាស | ១ | ១២ | ២០១៤ | EDC |
| ៣ | ខ្សែបញ្ជូនអគ្គិសនីជាកងជុំវិញរាជធានីភ្នំពេញ | ២ | ៤២ | ២០១៥ | ធនាគារចិន អ៊ិចស៊ីម |
| ៤ | អនុស្ថានីយសៀមរាប - អនុស្ថានីយសៀមរាបថ្មីខាងកើត | ១ | ២៥ | ២០១៦ | BOT |
| ៥ | អនុស្ថានីយទី២ - សួនច្បារសម្តេច ហ៊ុន សែន និង អនុស្ថានីយ | ២ | ៨,៥០ | ២០១៦ | BT |
| ៦ | អនុស្ថានីយទី៧ (ខាងត្បូងភ្នំពេញ) - អនុស្ថានីយព្រៃវែង - អនុស្ថានីយបាវិត | ២ | ១៥៥ | ២០១៧ | ធនាគារចិន អ៊ិចស៊ីម |
| ៧ | ព្រំប្រទល់ឡាវ - អនុស្ថានីយព្រះវិហារ | ១ | ៦០ | ២០១៧ | CHMC ដំហានទី៣ |
| ៨ | អនុស្ថានីយកំពង់ធំ - អនុស្ថានីយព្រះវិហារ និងអនុស្ថានីយកំពង់សីង្ហ - អនុស្ថានីយស្វាយអន្ទរ | ១ | ១៤០ | ២០១៧ | CHMC ដំហានទី៤ |
| ៩ | រោងចក្រវារីអគ្គិសនីគិរីរម្យ៣ - អនុស្ថានីយចំការល្ហុង | ១ | ២៧ | ២០១៨ | កំពុងស្វែងរកដៃគូអភិវឌ្ឍន៍ |
| ១០ | អនុស្ថានីយកំពង់ចាម - អនុស្ថានីយព្រែកប្រសប់(ក្រចេះ) | ១ | ១០០ | ២០១៨ | AFD |
| ១១ | ខ្សែបញ្ជូនកប់ដីពីអនុស្ថានីយទី១ - អគ្គិសនីកម្ពុជា - សួនច្បារសម្តេច ហ៊ុនសែន - អនុស្ថានីយអូឡាំពិក - អង្គភាពមជ្ឈមណ្ឌល ជាតិបញ្ជូន - អនុស្ថានីយទី៣ | ១ | ១៤ | ២០១៨ | JICA ដំហានទី១ |
| ១២ | ពីចំណុចកណ្តាលនៃអនុស្ថានីយទី៥ និងអនុស្ថានីយទី១ - អនុស្ថានីយទួលគោក | ២ | ០,១០ | ២០២០ | JICA ដំហានទី២ |

## ផែនការអភិវឌ្ឍន៍ផ្នែកប្រព័ន្ធខ្សែបញ្ជូន សម្រាប់ឆ្នាំ ២០១៤ - ២០២០ (ត)

| ល.រ | ខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ ១១៥ kV | ចំនួនសៀគ្វី | ប្រវែងខ្សែ (km) | ឆ្នាំដំណើរការ | ដៃគូអភិវឌ្ឍន៍ |
|---|---|---|---|---|---|
| ១៣ | អនុស្ថានីយទី៥ - អនុស្ថានីយជ្រោយចង្វារ | ២ | ១៨ | ២០២០ | កំពុងស្វែងរកដៃគូអភិវឌ្ឍន៍ |
| ១៤ | អនុស្ថានីយបន្ទាយមានជ័យ - អនុស្ថានីយឧត្តរមានជ័យ | ១ | ១០៥ | ២០២០ | កំពុងស្វែងរកដៃគូអភិវឌ្ឍន៍ |
| ប្រវែងខ្សែសរុប | | | ៧១៣,៦០ km | | |

| ល.រ | ខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ ២៣០ kV | ចំនួនសៀគ្វី | ប្រវែងខ្សែ (km) | ឆ្នាំដំណើរការ | ដៃគូអភិវឌ្ឍន៍ |
|---|---|---|---|---|---|
| ១ | រោងចក្រវារីអគ្គិសនីស្ទឹងឫស្សីជ្រុំលើក្រោម - រោងចក្រវារីអគ្គិសនីស្ទឹងតាតៃ | ២ | ៣៨ | ២០១៤ | BOT |
| ២ | ជុំវិញរាជធានីភ្នំពេញ (ខាងលិច - ខាងត្បូងភ្នំពេញ) | ២ | ៤៨ | ២០១៤ | ធនាគារចិនអ៊ិចស៊ីម |
| ៣ | អនុស្ថានីយទី៤ - អនុស្ថានីយស្ទឹងហាវ (តាមបណ្តោយផ្លូវជាតិលេខ៤) | ២ | ១៧២ | ២០១៦ | BOT |
| ៤ | អនុស្ថានីយបាត់ដំបង - អនុស្ថានីយខាងកើតសៀមរាប | ២ | ១០០ | ២០១៧ | ធនាគារចិនអ៊ិចស៊ីម |
| ៥ | អនុស្ថានីយខាងកើតសៀមរាប - អនុស្ថានីយកំពង់ធំ | ២ | ១៣០ | ២០១៧ | ធនាគារចិនអ៊ិចស៊ីម |
| ៦ | អនុស្ថានីយកំពង់ធំ - អនុស្ថានីយកំពង់ចាម | ២ | ១០០ | ២០១៧ | ធនាគារចិនអ៊ិចស៊ីម |
| ៧ | អនុស្ថានីយកំពង់ចាម - អនុស្ថានីយក្រចេះ | ២ | ១១០ | ២០១៧ | BOT |
| ៨ | អនុស្ថានីយក្រចេះ - អនុស្ថានីយស្ទឹងត្រែង | ២ | ១៣០ | ២០១៧ | ធនាគារឥណ្ឌាអ៊ិចស៊ីម |
| ៩ | អនុស្ថានីយស្ទឹងត្រែង - រោងចក្រវារីអគ្គិសនីសេសានក្រោម២ | ២ | ១៨ | ២០១៧ | BOT |
| ១០ | ជុំវិញរាជធានីភ្នំពេញជំហានទី២ (ខាងជើង - ជ្រោយចង្វារ - ខាងកើត - ខាងជើង) | ២ | ៦៥ | ២០១៨ | ធនាគារចិនអ៊ិចស៊ីម |
| ១១ | អនុស្ថានីយចំការលួង - អនុស្ថានីយបុទុមសាគរ | ២ | ៨៧ | ២០១៨ | AFD |
| ១២ | អនុស្ថានីយបុទុមសាគរ - រោងចក្រវារីអគ្គិសនីតាតៃ | ២ | ៧០ | ២០១៨ | កំពុងស្វែងរកដៃគូអភិវឌ្ឍន៍ |
| ១៣ | អនុស្ថានីយកោះកុង - អនុស្ថានីយទីក្រុងកោះកុង | ២ | ២១ | ២០១៨ | AFD |
| ១៤ | អនុស្ថានីយក្រចេះ - អនុស្ថានីមណ្ឌលគិរី | ២ | ១៤០ | ២០១៩ | ធនាគារចិនអ៊ិចស៊ីម |
| ១៥ | អនុស្ថានីយរតនគិរី - អនុស្ថានីយស្ទឹងត្រែង | ២ | ១០៥ | ២០១៩ | ធនាគារចិនអ៊ិចស៊ីម |

## ផែនការអភិវឌ្ឍន៍ផ្នែកប្រព័ន្ធខ្សែបញ្ជូន សម្រាប់ឆ្នាំ ២០១៤ - ២០២០ (ត)

| ល.រ | ខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ ២៣០ kV | ចំនួនសៀគ្វី | ប្រវែងខ្សែ (km) | ឆ្នាំដំណើរការ | ដៃគូអភិវឌ្ឍន៍ |
|---|---|---|---|---|---|
| ១៦ | អនុស្ថានីយស្ទឹងត្រែង - ព្រំប្រទល់ឡាវ PDR | ២ | ៤៨ | ២០១៩ | កំពុងស្វែងរកដៃគូអភិវឌ្ឍន៍ |
| ១៧ | ចំណុចកណ្ដាលនៃអនុស្ថានីយទី៦(ខាងជើងភ្នំពេញ) និងអនុស្ថានីយទី៤ - អនុស្ថានីយទី៥ | ២ | ១០,២០ | ២០២០ | JICA ជំហានទី២ |
| ១៨ | ខ្សែបញ្ជូនកប់ដីពីអនុស្ថានីយទី៥ - អង្គភាពមជ្ឈមណ្ឌលជាតិបញ្ជូន | ២ | ៩,២៨ | ២០២០ | JICA ជំហានទី២ |
| ប្រវែងខ្សែសរុប | | | ១.៣៦១,៤៨ km | | |

## ការតភ្ជាប់បណ្ដាញអគ្គិសនីជាមួយប្រទេសថៃឡង់ដ៍

កិច្ចព្រមព្រៀងសហប្រតិបត្តិការថាមពលជាមួយប្រទេសថៃឡង់ដ៍ ត្រូវបានចុះហត្ថលេខា នៅថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០០។ កិច្ចព្រមព្រៀងនេះ បានផ្ដល់នូវក្របខណ្ឌការងារសម្រាប់ការធ្វើពាណិជ្ជកម្មថាមពល និងជំនួយបច្ចេកទេសរវាងប្រទេសទាំងពីរនេះ និងបើកឲ្យថាមពលអគ្គិសនីចូលទៅប្រទេសទីបី។ កិច្ចព្រមព្រៀងទិញ-លក់ថាមពល បានចុះហត្ថលេខានៅឆ្នាំ ២០០២ និងបានកែសម្រួលនៅឆ្នាំ២០០៧ ។ កិច្ចព្រមព្រៀងនេះ បានជំរុញឲ្យប្រើប្រាស់រួមគ្នា នូវធនធានធម្មជាតិដែលមានស្រាប់របស់ប្រទេសទាំងពីរ។ នៅពេលដែលប្រភពបញ្ចូលគ្នានឹងត្រូវបង្កើតឡើង ប្រទេសទាំងពីរអាចចូលរួមដោយទូលាយលើការផ្គត់ផ្គង់ថាមពល និងការទទួលថាមពល ។

បច្ចុប្បន្នថាមពលអគ្គិសនីរវាងប្រទេសកម្ពុជា និងប្រទេសថៃឡង់ដ៍ ត្រូវបានបញ្ជូនដោយតង់ស្យុង ២២ kV និង ១១៥ kV ។ កិច្ចព្រមព្រៀងមួយ បានចុះហត្ថលេខាជាមួយខេត្តត្រាតនៃប្រទេសថៃឡង់ដ៍ ដើម្បីផ្គត់ផ្គង់ថាមពលឲ្យខេត្តកោះកុង និងក្រុងប៉ោយប៉ែតនៃប្រទេសកម្ពុជា ដោយប្រើបណ្ដាញ ២២ kV ។ តំបន់ខាងលើបានភ្ជាប់ថាមពលតាំងពីឆ្នាំ ២០០១ ។ ខ្សែបញ្ជូន ១១៥ kV ចេញពីអនុស្ថានីយអារញ្ញប្រាថេត ប្រទេសថៃឡង់ដ៍ ភ្ជាប់ទៅខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង និងខេត្តសៀមរាប បានដាក់ឲ្យដំណើរការក្នុងឆ្នាំ ២០០៧។

## ការតភ្ជាប់បណ្ដាញអគ្គិសនីជាមួយប្រទេសវៀតណាម

កិច្ចសហប្រតិបត្តិការថាមពលជាមួយប្រទេសវៀតណាម បានចុះហត្ថលេខានៅថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៩។ កិច្ចព្រមព្រៀងនេះ មានបំណងសហប្រតិបត្តិការក្នុងវិស័យថាមពល រវាងប្រទេសទាំងពីរ ។ ការផ្គត់ផ្គង់ថាមពលឲ្យតំបន់តាមបណ្ដោយព្រំដែន ដោយខ្សែបណ្ដាញតង់ស្យុងមធ្យម និងការតភ្ជាប់រវាងបណ្ដាញតង់ស្យុងខ្ពស់ត្រូវបានជំរុញ។

តាំងពីឆ្នាំ ២០០២ អគ្គិសនីកម្ពុជា បាននាំថាមពលពី PC2 ដើម្បីផ្គត់ផ្គង់នៅស្រុកមេមត់ និងស្រុកពញាក្រែក ខេត្តកំពង់ចាម បាវិតនៅខេត្តស្វាយរៀង កំពង់ត្រាចនៅខេត្តកំពត កោះធំ និងជ្រៃធំនៅខេត្តកណ្ដាល ស្រុកស្នួលនៅខេត្តក្រចេះ ស្រុកកែវសីមានៅខេត្តមណ្ឌលគិរី ស្រុកកំពង់រោទ៍នៅខេត្តស្វាយរៀង។ ការតភ្ជាប់ដើម្បីនាំថាមពលពីភ្នំដិននៅខេត្តតាកែវ ត្រូវបានដាក់ឲ្យដំណើរការនៅឆ្នាំ ២០០៩ ។ គម្រោងភ្ជាប់បណ្ដាញខ្សែបញ្ជូន ២៣០ kV សម្រាប់នាំចូលថាមពលពីប្រទេសវៀតណាម មកភ្នំពេញ ត្រូវបានដាក់ឲ្យដំណើរការនៅខែ មីនា ឆ្នាំ ២០០៩។

## ការតភ្ជាប់បណ្ដាញអគ្គិសនីជាមួយប្រទេសឡាវ

កិច្ចសហប្រតិបត្តិការថាមពល ជាមួយប្រទេសឡាវ ត្រូវបានចុះហត្ថលេខានៅថ្ងៃទី ២១ ខែតុលា ឆ្នាំ ១៩៩៩ ។ កិច្ចព្រមព្រៀងនេះ មានគោលបំណងសហប្រតិបត្តិការក្នុងវិស័យថាមពល រវាងប្រទេសទាំងពីរ។ ការផ្គត់ផ្គង់

ថាមពលដល់តំបន់តាមបណ្តោយព្រំដែន ដោយបណ្តាញតង់ស្យុងមធ្យម ២២ kV និងការតភ្ជាប់បណ្តាញជាមួយបណ្តាញតង់ស្យុងខ្ពស់ ត្រូវបានជំរុញ។ ការតភ្ជាប់បណ្តាញតង់ស្យុង ២២ kV ពីប្រទេសឡាវ មកខេត្តស្ទឹងត្រែង ត្រូវបានដាក់ឲ្យដំណើរការនៅឆ្នាំ២០១០។

ប្រទេសទាំងពីរបានពិភាក្សាគ្នា និងព្រមព្រៀងលើការតភ្ជាប់បណ្តាញថាមពល ពីភាគខាងត្បូងប្រទេសឡាវ (បានហាតនៅខេត្តចំប៉ាសាក់) ទៅកាន់ខេត្តស្ទឹងត្រែងនៃប្រទេសកម្ពុជា តាមខ្សែបញ្ជូនតង់ស្យុង ១១៥ kV នៅពេលអនាគត។

## ការតភ្ជាប់បណ្តាញអនុតំបន់

ការសិក្សាតភ្ជាប់រវាងបណ្តាញ ដែលនៅដាច់ដោយឡែកពីប្រទេសមួយទៅប្រទេសមួយនៅក្នុងអនុតំបន់អាងទន្លេមេគង្គ (កម្ពុជា ឡាវ ថៃឡង់ដ៍ វៀតណាម យូណាន - ប្រទេសចិន និងប្រទេសភូមា) និងសូម្បីតែបណ្តាញប្រទេសម៉ាឡេស៊ី និងសឹង្ហបូរី ក៏ត្រូវបានយកមកធ្វើការសិក្សាផងដែរ ដោយមានគោលបំណងធ្វើឲ្យប្រសើរឡើងនូវការប្រើប្រាស់ប្រភពថាមពល។ របាយការណ៍ស្តីពី ផែនការមេនៃការតភ្ជាប់បណ្តាញរបស់អាស៊ានត្រូវបានសិក្សាបញ្ចប់នៅឆ្នាំ ២០០២ ដែលបង្ហាញពីការសិក្សាមួយយ៉ាងច្បាស់ ស្តីអំពីការតភ្ជាប់បណ្តាញរបស់អាស៊ាន។ បច្ចុប្បន្នមានការពិនិត្យឡើងវិញ អំពីផែនការមេនៃការតភ្ជាប់បណ្តាញរបស់អាស៊ាននេះ ដោយក្រុមសិក្សានៃបណ្តាប្រទេសអាស៊ាន។

ការសិក្សាផ្តល់ភាគច្រើន លើការវាយតម្លៃលើអាទិភាព និងលទ្ធភាពជោគជ័យនៃការតភ្ជាប់ខ្សែបណ្តាញទៅវិញទៅមកនៅក្នុងតំបន់ ដោយផ្អែកលើការសិក្សាបុរេសមិទ្ធលទ្ធភាព។ ការសិក្សាបានស្នើឲ្យមានការអភិវឌ្ឍន៍បណ្តាញថាមពលអាស៊ាន (APG) ដោយបានបង្កើតគណៈកម្មាធិការទីប្រឹក្សាបណ្តាញថាមពលអាស៊ាន។ យ៉ាងណាក៏ដោយ ក្នុងចំណោមការសិក្សាតភ្ជាប់បណ្តាញចំនួន ១០ របស់អាស៊ានការតភ្ជាប់បណ្តាញរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម ជាប់លំដាប់ទី៤ និងបានចាត់ថ្នាក់ថាជាគម្រោង ដែលមានសក្តានុពលពីរយៈពេលខ្លីទៅរយៈពេលមធ្យម ដែលគួរបញ្ចប់គម្រោងនេះមុនឆ្នាំ ២០១០ ។




រូបភាពទី ១០: ផែនការអភិវឌ្ឍន៍ខ្សែបញ្ជូន ឆ្នាំ ២០១៥-២០២០

**អគ្គិសនីកម្ពុជា**
**តារាងតុល្យការ**
នាថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៣

| | ២០១៣<br>ពាន់រៀល | ២០១២<br>ពាន់រៀល |
|---|---|---|
| **ទ្រព្យសកម្ម** | | |
| **ទ្រព្យសកម្មរយៈពេលវែង** | | |
| ទ្រព្យ រោងចក្រ និងបរិក្ខារ | ១.៩៧៨.១០៣.១០៦ | ១.៦៥២.៧៣៦.០៤៤ |
| ទ្រព្យសកម្មអរូបិយ | ១២០.៤០០ | ១៩៥.៩៩៣ |
| ទ្រព្យសកម្មរយៈពេលវែងផ្សេងៗ | ១៩២.២៥១.៥២៨ | ១៩៤.២៥៥.៧៥៣ |
| | **២.១៧០.៤៧៥.០៣៤** | **១.៨៤៧.១៨៧.៧៩០** |
| **ទ្រព្យសកម្មចរន្ត** | | |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ៧៧០.៩៥៥.៩៦៦ | ៥៧៨.៧៣៨.៥២៣ |
| គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ | ៥៥៣.៧២២.៩៥៩ | ៣៧៣.២១៥.៩៧៤ |
| សន្និធិ | ១៦៨.១៦៤.៣២៦ | ១៦៨.១៣៤.២៧៩ |
| | **១.៤៩២.៨៤៣.២៥១** | **១.១២០.០៨៨.៧៧៦** |
| **ទ្រព្យសកម្មសរុប** | **៣.៦៦៣.៣១៨.២៨៥** | **២.៩៦៧.២៧៦.៥៦៦** |
| **មូលធន** | | |
| ដើមទុន | ៦៨០.១៨៤.៧២០ | ៦៨០.១៨៥.០៥៤ |
| ប្រាក់ចំណេញរក្សាទុក | ៨១៥.៣៤០.៧៧១ | ៥១២.០១៧.២៩៨ |
| | **១.៤៩៥.៥២៥.៤៩១** | **១.១៩២.២០២.៣៥២** |
| **ទ្រព្យអកម្ម** | | |
| **បំណុលរយៈពេលវែង** | | |
| ប្រាក់កម្ចី | ១.២២៥.៤៧០.៧៩៨ | ៩៥៨.៦២៦.១៥៦ |
| ប្រាក់កក់របស់អតិថិជន | ១០៣.២៣០.៥៣៣ | ៨៩.៧២៤.១៩៦ |
| សំវិធានធនសម្រាប់សោធននិវត្តន៍ | ២.៥៩៥.៥៦៤ | ១.៩៦១.៣៨៥ |
| បំណុលពន្ធពន្យារ, សុទ្ធ | ១៧.១៨៨.៥០៨ | ១០.៨១២.៧០៦ |
| | **១.៣៤៨.៤៨៥.៤០៣** | **១.០៦១.១២៤.៣៩៣** |
| **បំណុលចរន្ត** | | |
| ប្រាក់កម្ចី | ១៤៤.២៨៨.៣០៤ | ១៤៥.១៧៧.៩៧៣ |
| គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវទូទាត់ផ្សេងៗ | ៦១៩.៤៧៣.៣៦៦ | ៥៣៦.៩២៤.០០៩ |
| ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំត្រូវទូទាត់ | ៥៥.៥៤៩.៧២១ | ៣១.៨៤៧.៨៣៩ |
| | **៨១៩.៣០៧.៣៩១** | **៧១៣.៩៤៩.៨២១** |
| **បំណុល និងមូលធនសរុប** | **៣.៦៦៣.៣១៨.២៨៥** | **២.៩៦៧.២៧៦.៥៦៦** |

## អគ្គិសនីកម្ពុជា
## របាយការណ៍លទ្ធផល
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៣

| | ២០១៣<br>ពាន់រៀល | ២០១២<br>ពាន់រៀល |
|---|---|---|
| **ចំណូល** | | |
| ចំណូលពីការលក់ថាមពលអគ្គិសនី | ២.៦២៤.៦៨០.៣០២ | ២.២៥៣.១៦៤.៦០៤ |
| ចំណូលពីការតភ្ជាប់បណ្តាញអគ្គិសនី | ៣៥.០២៥.៧៧៨ | ១៧.៦៦៥.៩២៨ |
| ចំណូលផ្សេងៗ | ១៣.៨០៩.៩៣៤ | ១១.៦៤៩.៩១៧ |
| | **២.៦៧៣.៥១៦.០១៤** | **២.២៨២.៤៨០.៤៤៩** |
| **ចំណាយប្រតិបត្តិការ** | | |
| ការទិញថាមពល | (១.៩៥២.៥៥៤.៣៤៨) | (១.៦៨១.៨៣២.៨០៣) |
| ចំណាយថ្លៃប្រេង | (៣៨.៧៩១.៩៧៦) | (៦៩.៣០៨.១១៤) |
| ចំណាយលើពន្ធនាំចូល | (៤៥.៦៣២.៧៥១) | (៤០.៣០៥.០៨២) |
| ចំណាយលើប្រាក់បៀវត្សរ៍ និងអត្ថប្រយោជន៍ផ្សេង | (១០១.៣៧១.២៣៣) | (៨៤.២៤៩.៣៤៩) |
| ចំណាយប្រតិបត្តិការផ្សេងៗ | (៦៥.៥៧៨.៦៤៦) | (៥៦.២៤៧.៤២០) |
| រំលស់លើទ្រព្យរោងចក្រ និងបរិក្ខារ | (៦៨.៩៤៧.៣៨៧) | (៥៨.៨៧២.៦០៥) |
| រំលស់លើទ្រព្យសកម្មអរូបិយ | (៧៥.៥៩៣) | (៩៦.៥២១) |
| **ចំណេញប្រតិបត្តិការ** | **៤០០.៥៦៤.០៨០** | **២៩១.៥៦៨.៥៥៥** |
| ចំណាយហិរញ្ញវត្ថុ-សុទ្ធ | (១៣.៤៣៩.៩៨៦) | (៣៣.៨៤៧.៨០៦) |
| **ប្រាក់ចំណេញមុនដកពន្ធ** | **៣៨៧.១២៤.០៩៤** | **២៥៧.៧២០.៧៤៩** |
| ពន្ធលើប្រាក់ចំណេញ | (៨៣.៨០០.៦២១) | (៥៥.២៦៩.០៩៥) |
| **ប្រាក់ចំណេញសុទ្ធ សម្រាប់ការិយបរិច្ឆេទ/ចំណូលរួមសរុប** | **៣០៣.៣២៣.៤៧៣** | **២០២.៤៥១.៦៥៤** |

## អគ្គិសនីកម្ពុជា
## របាយការណ៍លំហូរសាច់ប្រាក់
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៣

| | ២០១៣ | ២០១២ |
|---|---|---|
| | ពាន់រៀល | ពាន់រៀល |
| **លំហូរទឹកប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | |
| ប្រាក់ចំណេញប្រចាំឆ្នាំ | ៣០៣.៣២៣.៤៧៣ | ២០២.៩៥១.៦៥៩ |
| និយ័តកម្មលើ: | | |
| ចំណាយរំលស់ | ៦៩.០២២.៩៨០ | ៥៨.៩៦៩.១២៦ |
| ចំណូលពីការផ្ទេរទ្រព្យសកម្មពីអតិថិជន | - | - |
| ខាតលើការលក់ទ្រព្យ រោងចក្រ និងបរិក្ខារ | ៧.៩៧៤.៧៣៤ | ១.៥៩៦.១៩៦ |
| ចំណេញពីការប្តូររូបិយប័ណ្ណបរទេស | ២.៨៥៣.៩៧១ | (៧.៨៦៥.៨០៨) |
| ចំណាយការប្រាក់ | ៩.៥៨០.៩៣៤ | ៣៩.៩៨២.៣៧០ |
| ចំណាយពន្ធប្រាក់ចំណូល | ៨៣.៨០០.៦២១ | ៥៥.២៦៩.០៩៥ |
| សំវិធានធន/(ការយកមកវិញនៃសំវិធានធន) | | |
| លើគណនីអតិថិជនជាប់សង្ស័យ | (២.៦១៥.៧៨១) | ២.៧៥៦.៨០៨ |
| សំវិធានធនសម្រាប់អត្ថប្រយោជន៍ចូលនិវត្តន៍ | ៦៣៩.១៧៩ | ៦០៤.៩៦៧ |
| សំវិធានធនសម្រាប់សន្និធិខូចខាត | ២.៨៩៣.២៤៩ | ៥១០.៥៧២ |
| | ៤៧៧.៤៦៨.៣៦០ | ៣៥៨.៧៧៤.៩៨០ |
| ប្រែប្រួលនៃ: | | |
| គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ | (៨២.៣៣០.៣៥៥) | (៥៥.៨៩៩.៨០៨) |
| សន្និធិ | (៦៥.៦៦៤.៨៧២) | (៨០.៩០៩.០០៣) |
| ទ្រព្យសកម្មរយៈពេលវែងផ្សេងៗ | ២.០០៤.២២៥ | ៧.៣៩៩.៩០៩ |
| គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវទូទាត់ផ្សេងៗ | ១១១.៩៩៥.០៨១ | ១៣៦.២០៩.៨៧៦ |
| ប្រាក់កក់របស់អតិថិជន | ១៣.៥០៦.៣៨៧ | ១១.៤៦៥.៤៣៨ |
| | | |
| សាច់ប្រាក់សុទ្ធទទួលបានពីប្រតិបត្តិការ | ៤៥៦.៩៧៨.៨២៦ | ៣៧៧.០៤០.៨៩២ |
| ការប្រាក់បានបង់ | (៣៩.១៣៥.១៨៣) | (៤២.២៤៧.៨៩៧) |
| ពន្ធបានបង់ | (៥៣.៦១៤.៤១២) | (៣១.៨១៤.០០៧) |
| **សាច់ប្រាក់សុទ្ធទទួលបានពីសកម្មភាពប្រតិបត្តិការ** | **៣៦៤.២២៩.២៣១** | **៣០២.៩៧៨.៩៨៨** |

## អគ្គិសនីកម្ពុជា
## របាយការណ៍លំហូរសាច់ប្រាក់ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៣

| | ២០១៣<br>ពាន់រៀល | ២០១២<br>ពាន់រៀល |
|---|---|---|
| **លំហូរទឹកប្រាក់ពីសកម្មភាពវិនិយោគ** | | |
| ការទិញ ទ្រព្យ រោងចក្រ និងបរិក្ខារ | (២១៧.៦៤០.០៧៨) | (១៤០.១៩៥.២១២) |
| សាច់ប្រាក់ទទួលបានពីការលក់ទ្រព្យ រោងចក្រ និងបរិក្ខារ | ២៥១.៥៣៣ | ២.៣៧១.៤៣៤ |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ** | **(២១៧.៣៨៨.៥៤៥)** | **(១៣៧.៧៧៣.៧៧៨)** |
| **លំហូរទឹកប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | |
| សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី | ១២៤.៤៣៩.៣១៣ | ៧៤.២៦៩.៥៩៣ |
| ការទូទាត់សងប្រាក់កម្ចី | (៧៩.០៦២.២២២) | (៦៩.៥៦៥.៧១១) |
| ជំនួយពីរាជរដ្ឋាភិបាល | (៣៣៤) | ១១.៩៧៣ |
| សាច់ប្រាក់សុទ្ធទទួលបានពីសកម្មភាពហិរញ្ញប្បទាន | **៤៥.៣៧៦.៧៥៧** | **៤.៧១៥.៨៥៥** |
| ការកើនឡើងសុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល | ១៩២.២១៧.៤៤៣ | ១៦៩.៩២១.០៦៥ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាដើមការិយបរិច្ឆេទ** | **៥៧៨.៧៣៨.៥២៣** | **៤០៨.៨១៧.៤៥៨** |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាចុងការិយបរិច្ឆេទ** | **៧៧០.៩៥៥.៩៦៦** | **៥៧៨.៧៣៨.៥២៣** |